# ជំពូកទី០៥
# ការចូលរួមពីសាធារណៈជន

Draft

## ៥.១. សេចក្តីផ្តើម

ការចូលរួមពីសាធារណៈជន គឺជាផ្នែកមួយដ៏សំខាន់ ដើម្បីឱ្យការវាយតំលៃហេតុប៉ះពាល់បរិស្ថានប្រព្រឹត្តទៅដោយមានប្រសិទ្ធភាព។ ក្នុងការសិក្សានេះក្រុមការងារនៃក្រុមហ៊ុន Hoang Anh Rattanakiri Co., Ltd. និងក្រុមហ៊ុនទីប្រឹក្សា CES Co., Ltd. បានចុះធ្វើការផ្សព្វផ្សាយ ស្ទាបស្ទង់មតិ និងជួបពិភាក្សាជាមួយសហគមន៍មូលដ្ឋាន អាជ្ញាធរមូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នជំនាញពាក់ព័ន្ធផ្សេងៗ។ គោលបំណងសំខាន់ គឺដើម្បីពន្យល់បកស្រាយអំពីសកម្មភាពគំរោង ស្តាប់មតិសាធារណៈអំពីបញ្ហាបរិស្ថាន និងសង្គម ដែលបង្ក ឬអាចនឹងបង្កឡើងដោយសារសកម្មភាពអាជីវកម្មរបស់គំរោង និងប្រមូលនូវកង្វល់ផ្សេងៗដែលទាក់ទងនឹងបញ្ហាបរិស្ថាន-សង្គម ដើម្បីស្វែងរកដំណោះស្រាយមួយដ៏ល្អ និង អាចទទួលយកបានសំរាប់ភាគីពាក់ព័ន្ធទាំងអស់។

## ៥.២. ការចូលរួមរបស់សាធារណៈជន

### ៥.២.១. ការផ្សព្វផ្សាយអំពីគំរោង និងការជួបពិគ្រោះយោបល់ជាមួយអាជ្ញាធរស្រុកបរកែវ

ការជួបសំភាសន៍ និងពិគ្រោះយោបល់ជាមួយ**លោក ហេង ប៊ុនថាន់** (អភិបាលស្រុកបរកែវ) កាលពីថ្ងៃទី19 ខែវិច្ឆិកា ឆ្នាំ2010 នៅសាលាស្រុកបរកែវ (រូបភាព29) ត្រូវបានធ្វើឡើង ដើម្បីសាកសួរ និងប្រមូលព័ត៌មានអំពីៈ

- ប្រជាសាស្ត្រ និងការតាំងទីលំនៅៈ ប្រជាពលរដ្ឋចាប់ផ្តើមមកតាំងទីលំនៅក្នុងស្រុកបរកែវចាប់តាំងពីយូរឆ្នាំមកហើយ ដែលនៅពេលនោះប្រជាពលរដ្ឋភាគច្រើនជាជនជាតិដើមភាគតិច។ ចំនួនប្រជាពលរដ្ឋទាំងនេះមានការកើនឡើងជាបន្តបន្ទាប់ និងមានការហូរចូលនូវប្រជាពលរដ្ឋចំណាកស្រុកមកពីតំបន់ផ្សេង ដែលរួមមានទាំងប្រជាពលរដ្ឋជនជាតិខ្មែរ និងខ្មែរ-អ៊ីស្លាម ហើយមកទល់បច្ចុប្បន្នប្រជាពលរដ្ឋមានចំនួនរហូតដល់ប្រមាណ3.000គ្រួសារ (ស្មើនឹងប្រមាណ15.000នាក់)។ ភាគច្រើននៃប្រជាពលរដ្ឋទាំងនេះ គឺរស់នៅតាមបណ្តោយផ្លូវជាតិ និងផ្លូវលំផ្សេងៗនៅក្នុងភូមិ-ឃុំ។ ការកើនឡើងនូវចំនួនប្រជាពលរដ្ឋទាំងនេះ គឺដោយសារមានការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចដូចជាវត្តមានផ្លូវជាតិ-ផ្លូវលំល្អៗ និងប្រភេទដីមានជីជាតិជាច្រើន ដែលផ្តល់ការងាយស្រួលដល់ពួកគាត់ក្នុងការប្រកបមុខរបរផ្សេងៗ។
- ស្ថានភាពសេដ្ឋកិច្ច-សង្គមៈ ប្រជាពលរដ្ឋនៅក្នុងស្រុកបរកែវនេះ កាលពីមុនប្រកបរបរធ្វើស្រែ-ចំការជាលក្ខណៈពនេចរ ប៉ុន្តែបច្ចុប្បន្នពួកគាត់បានប្តូរមកធ្វើស្រែ-ចំការជាលក្ខណៈអចិន្ត្រៃយ៍វិញដូចជា ដាំដំណាំ (ដំឡូង សណ្តែក ស្វាយចន្ទី) កាប់ឈើ និងបរបាញ់តិចតួច បំរើសេវាកម្ម (ធ្វើជាកម្មករ) ធ្វើអាជីវកម្ម និងប្រមូលអនុផលព្រៃឈើ។ គួរកត់សំគាល់ផងដែរថា ការប្រកបរបរនេសាទ ឬចាប់ត្រី ស្ទើរតែមិនមាន ចំណែកឯស្ថានភាពព្រៃកាលពីពេលមុនមានគំរបព្រៃច្រើន ប៉ុន្តែបច្ចុប្បន្នមានការធ្លាក់ចុះយ៉ាងច្រើន (ស្ទើរតែក្លាយជាព្រៃសឹករេចរិល)។ សត្វព្រៃដែលនៅមានវត្តមាន និងនៅជួបប្រទះនាពេលបច្ចុប្បន្នមានតែសត្វឈ្លូស និងជ្រូកព្រៃ។ ការបាត់បង់សត្វព្រៃទាំងនេះ

Draft

បណ្ដាលមកពីការបរបាញ់ និងដាក់អន្ទាក់ស្ទើរគ្រប់ទីកន្លែងពីសំណាក់ប្រជាពលរដ្ឋ និងជាពិសេសជនខិលខូច។ ប្រជាពលរដ្ឋប្រើប្រាស់ទឹកដោយពឹងផ្អែកស្ទើរតែទាំងស្រុងទៅលើទឹក ដែលមានប្រភពមកពីអូរ និងអណ្ដូងច្រប ផ្សេងៗ និងទឹកភ្លៀង (សំរាប់ធ្វើស្រែ-ចំការ និងដាំដំណាំ)។ បញ្ហាសុខភាពដែលកើតមាននៅក្នុងតំបន់រួមមាន ជំងឺកញ្ជ្រិល គ្រុនចាញ់ គ្រុនផ្ដាសសាយ និងជំងឺផ្លូវដង្ហើម ហើយភាគច្រើននៃជំងឺទាំងនេះកើតឡើងដោយសារការខ្វះអនាម័យ និងការរៀបចំផ្ទះមិនបានល្អ។

- ការពិគ្រោះយោបល់ និងពិភាក្សានេះក៏បានបង្ហាញឱ្យឃើញថា លោកធ្លាប់ដឹងលឺអំពីគំរោងអភិវឌ្ឍន៍របស់ក្រុមហ៊ុន Hoang Anh Rattanakiri Co., Ltd. ដែលបានមកធ្វើការសិក្សាស្រាវជ្រាវរុករករ៉ែនៅក្នុងតំបន់បរកែវ ប៉ុន្តែលោកមិនបានដឹងច្បាស់លាស់អំពីគំរោងធ្វើអាជីវកម្មរ៉ែដែករបស់ក្រុមហ៊ុននោះទេ។ ទោះបីជាយ៉ាងណា លោកមិនមានមតិជំទាស់ចំពោះវត្តមានក្រុមហ៊ុនមកធ្វើការអភិវឌ្ឍន៍នៅក្នុងតំបន់នោះទេ។ បន្ថែមពីលើនេះទៀត លោកក៏មានសេចក្ដីរីករាយចំពោះវត្តមានគំរោងដែរ ពីព្រោះវត្តមានគំរោងអាចនឹងជួយលើកស្ទួយសេដ្ឋកិច្ចជាតិ និងខេត្ត-ស្រុក និងមូលដ្ឋាន តាមរយៈការប្រមូលចំណូលថវិកា និងឱកាសចូលបំរើការងារនានា។ ទន្ទឹមនឹងនេះផងដែរ បញ្ហាផ្សេងៗធ្លាប់កើតមាននៅក្នុងដំណាក់កាលសិក្សាស្រាវជ្រាវរុករករ៉ែរវាងក្រុមហ៊ុន និងប្រជាពលរដ្ឋមូលដ្ឋានដូចជា ការប៉ះពាល់ដីស្រែ-ចំការរបស់ប្រជាពលរដ្ឋ ការមិនជូនដំណឹង និងសហការជាមួយប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋានជាដើម។ ទោះបីជាយ៉ាងណា បញ្ហាទាំងនេះត្រូវបានស្ងប់ស្ងាត់ទៅវិញបន្ទាប់ពីមានការចុះមកសាកសួរ និងដោះស្រាយ ដែលដឹកនាំដោយ**ឯកឧត្តម ស៊ុយ សែម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**។ អាស្រ័យហេតុនេះហើយ លោកបានលើកឡើងនូវក្ដីបារម្ភ សំណូមពរ និងអនុសាសន៍មួយចំនួនដូចតទៅ:
  - ១ សុំឱ្យក្រុមហ៊ុនសហការជាមួយអាជ្ញាធរស្រុកឱ្យបានស្និតរមួត ដើម្បីងាយស្រួលក្នុងការស្វែងរកដំណោះស្រាយរួមគ្នានៅពេលដែលមានបញ្ហាផ្សេងៗកើតឡើង ជាពិសេសបញ្ហាដីធ្លីរបស់ប្រជាពលរដ្ឋមូលដ្ឋាន។
  - ១ សំណូមពរឱ្យក្រុមហ៊ុនធ្វើការសិក្សា និងសហការជាមួយស្ថាប័នជំនាញពាក់ព័ន្ធដូចជា រដ្ឋបាលព្រៃឈើ ក្រសួងបរិស្ថាន និងធ្វើការដោះស្រាយបញ្ហាផ្សេងៗ នៅពេលដែលមានសកម្មភាពប៉ះពាល់ណាមួយកើតមានឡើង។

### ៥.២.១.១. ការផ្សព្វផ្សាយអំពីគំរោង និងការជួបពិភាក្សាជាមួយអាជ្ញាធរឃុំកិចុង

ការផ្សព្វផ្សាយអំពីគំរោង និងការពិគ្រោះយោបល់ជាមួយ**លោក រចំ ឡៃ** (មេឃុំ) **លោក សេង ឌី** (ជំទប់ទី01) និង**លោក រមាស់ ភ្លេង** (សមាជិកឃុំ) កាលពីថ្ងៃទី21 ខែវិច្ឆិកា ឆ្នាំ2010 នៅសាលាឃុំ (រូបភាព29) ត្រូវបានធ្វើឡើង ដើម្បីសាកសួរ និងប្រមូលព័ត៌មានបន្ថែម (ផ្ដោតសំខាន់ទៅលើភូមិដែលនៅក្បែរទីតាំងគំរោង ហើយការរៀបរាប់ដូចមានខាងលើ មិនត្រូវបានលើកមកនិយាយម្ដងទៀតទេ):

Draft

❖ ស្ថានភាពតំបន់ និងស្ថានភាពធម្មជាតិ-សង្គមៈ ប្រជាពលរដ្ឋមកតាំងទីលំនៅក្នុងតំបន់នេះចាប់តាំងពីសម័យជីដូន-ជីតាមកម្ល៉េះ ហើយចំនួនប្រជាពលរដ្ឋមានការកើនឡើងចាប់ពីឆ្នាំ1970រហូតមកដល់ពេលបច្ចុប្បន្ន។ នៅក្នុងឃុំនេះ ភូមិក្រៀល គឺជាភូមិនៅក្បែរទីតាំងគំរោង ហើយប្រជាពលរដ្ឋមួយចំនួនធំមានដីធ្លីស្រែ-ចំការនៅក្នុងទីតាំងគំរោងតែម្តង។ ស្ថានភាពអាកាសធាតុនៅក្នុងតំបន់នេះមានការជួបប្រទះភាពរាំងស្ងួតច្រើន ដែលជាហេតុធ្វើឱ្យការដាំដុះដំណាំសណ្តែក និងស្រូវមិនសូវទទួលបាលទិន្នផលល្អច្រើនទេ។ ប្រព័ន្ធផ្លូវទឹកមិនមានច្រើនទេ ហើយមានតែអូរកប ទេដែលនៅមានទឹក ចំណែកឯអូរតូចៗផ្សេងទៀតវិញទទួលរងនូវការគោកស្ងួតស្ទើរតែទាំងស្រុងនៅរដូវប្រាំង។ អូរកប ធ្លាប់មានត្រីមួយចំនួន ប៉ុន្តែបច្ចុប្បន្នមិនមានទៀតទេ ដោយធ្លាប់កើតមានករណីចាប់ត្រីខុសច្បាប់។ មុខរបរចំបងរបស់ប្រជាពលរដ្ឋ គឺការធ្វើចំការដាំដំណាំសណ្តែក (ដំណាំកៅស៊ូសំរាប់គ្រួសារធូរធារ) ដំណាំស្រូវ ប៉ុន្តែមិនមានដាំបន្លែច្រើនទេ។ ចំណែកឯមុខរបរចាប់ត្រីវិញ មិនមានទេ ដោយសារស្ថានភាពប្រព័ន្ធទឹក និងធនធានត្រីមិនសូវមាន។

ស្ថានភាពព្រៃឈើនៅក្នុងតំបន់នេះក៏ទទួលរងនូវការប្រែក្លាយជាច្រើនដែរ។ ទោះបីជាដើមឈើធំៗនៅមានមួយចំនួនក៏ដោយ ក៏ដើមឈើធំៗមានតំលៃមិនមានទៀតទេ ពោល គឺមើលពីចំងាយប្រៀបដូចជាព្រៃស្រោង ប៉ុន្តែជាក់ស្តែងជាព្រៃសឹករេចរិល។ ការបាត់បង់នេះដោយសារការកាប់ឈើពីសំណាក់ប្រជាពលរដ្ឋដើម្បីជាចំណូលចរិកា និងដោយសារការកាប់ឈើពីសំណាក់ជនខិលខូច។ ចំណែកឯសត្វព្រៃវិញ ក៏មានទំនោរបាត់បង់ស្របគ្នាជាមួយនឹងស្ថានភាពព្រៃឈើដែរ។

❖ ព័ត៌មានពាក់ព័ន្ធ និងវត្តមានគំរោងៈ លោកធ្លាប់ដឹងលឺអំពីគំរោងអភិវឌ្ឍន៍របស់ក្រុមហ៊ុន ប៉ុន្តែពួកគាត់មិនទាន់បានចុះពិនិត្យជុំវិញទីតាំងគំរោងជាក់ស្តែងនៅឡើយទេ ពោល គឺគ្រាន់តែបានឃើញទីស្នាក់ការរបស់ក្រុមហ៊ុនប៉ុណ្ណោះ។ បញ្ហាប៉ះពាល់ដីធ្លីស្រែ-ចំការធ្លាប់កើតមានរវាងក្រុមហ៊ុន និងប្រជាពលរដ្ឋ ហើយជាដំណោះស្រាយក្រុមហ៊ុនបានសន្យាថាៈ I). ក្រុមហ៊ុននឹងធ្វើការយករ៉ែតែម្យ៉ាងគត់ II). ប្រសិនបើដីធ្វើអាជីវកម្មរ៉ែមានការប៉ះពាល់ដល់ប្រជាពលរដ្ឋ ក្រុមហ៊ុននឹងធ្វើសំណងទូរដងទៅតាមប្រភេទ និងទិន្នផល ហើយនឹងធ្វើការចាក់ដីបំពេញវិញបន្ទាប់ពីយករ៉ែអស់ និង III). មិនឱ្យសកម្មភាពអាជីវកម្មរបស់ខ្លួនបង្កឱ្យមានការបំពុលទឹកជាដើម។ ទោះបីជាបញ្ហានេះបានស្ងប់ស្ងាត់ទៅមួយរយៈដោយសារមានការសំរបសំរួលពីសំណាក់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលក៏ដោយ ក៏សកម្មភាពបន្ទាប់របស់ក្រុមហ៊ុនអាចនឹងបង្កឱ្យមានអ្វីផ្សេងទៀតកើតដែរ។ ដោយហេតុនេះហើយ លោកក៏បានលើកឡើងនូវការបារម្ភមួយចំនួនដូចខាងក្រោមៈ

- ការបារម្ភៈ
    - បារម្ភខ្លាចសកម្មភាពគំរោងធ្វើឱ្យមានការប៉ះពាល់ដល់គុណភាពទឹកអូរ។

Draft

- ○ បារម្ភទៅលើការបំពុលខ្យល់ដោយសារការហុយធូលី មិនសូវមាខ្លាំងក្លានោះទេ ប្រសិនបើក្រុមហ៊ុនអនុវត្តន៍ទៅតាមបទដ្ឋានបច្ចេកទេស និងតាមច្បាប់។
- ○ បារម្ភអំពីដីធ្លីឯកជនដែលប្រជាពលរដ្ឋបានលក់ទៅឱ្យឈ្មួញ (អាជ្ញាធរដែនដី មិនបានដឹងច្បាស់លាស់) ដូច្នេះសូមឱ្យក្រុមហ៊ុនសិក្សាឱ្យបានច្បាស់លាស់ និងដោះស្រាយជាមួយពួកគាត់ឱ្យបានល្អ ដើម្បីចៀសវាងបញ្ហាជំលោះរឿងដីធ្លីផ្សេងៗកើតឡើង។ តាមការប៉ាន់ស្មាន គំរោងអាចប៉ះពាល់ដល់ដីធ្លីស្រែ-ចំការរបស់ប្រជាពលរដ្ឋប្រមាណ45%នៃចំនួនប្រជាពលរដ្ឋទាំងមូល។

- សំណូមពរ:
  - ○ សុំឱ្យក្រុមហ៊ុនជួយរកវិធីសាស្ត្រដោះស្រាយណា ដែលអាចជួយកែលំអជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្រីក្រ ដែលកំពុងរស់នៅក្នុង និងក្បែរទីតាំងគំរោង។

### ៥.២.១.២. ការផ្សព្វផ្សាយអំពីគំរោង និងការជួបពិភាក្សាជាមួយអាជ្ញាធរឃុំកក់

ការផ្សព្វផ្សាយអំពីគំរោង និងការពិភាក្សាត្រូវបានធ្វើឡើងជាមួយ**លោក ឡេ ហៅយ៉** (មេឃុំ) **លោក ហៀង សុភាន់** (មេភូមិកក់) និង**លោក ហៀង សុទាន់** (មេភូមិរវៀងតូច) កាលពីថ្ងៃទី23 ខែវិច្ឆិកា ឆ្នាំ2010 នៅសាលាឃុំកក់ (រូបភាព29)។ កិច្ចពិគ្រោះពិភាក្សានេះ ផ្តោតទៅភូមិដែលនៅក្បែរទីតាំងគំរោង និងដើម្បីធ្វើការសាកសួរ និងប្រមូលព័ត៌មានបន្ថែម (ការរៀបរាប់ដូចមានខាងលើ មិនត្រូវបានលើកមកនិយាយម្តងទៀតទេ):

- ❖ ស្ថានភាពតំបន់ និងស្ថានភាពធម្មជាតិ-សង្គម: ចំនួនប្រជាពលរដ្ឋក្នុងកំឡុងពេលប៉ុន្មានឆ្នាំថ្មីៗនេះមានការកើនឡើង ប៉ុន្តែកំនើនប្រជាពលរដ្ឋចំណាកស្រុកមិនមានទេ។ គួរកត់សំគាល់ផងដែរថា នៅក្នុងឃុំនេះ ភូមិកាចក គឺជាភូមិមួយនៅក្បែរទីតាំងគំរោង ហើយប្រជាពលរដ្ឋមួយចំនួនធំ (ប្រមាណ80%នៃប្រជាពលរដ្ឋក្នុងភូមិសរុប) មានដីធ្លីស្រែ-ចំការនៅក្នុងទីតាំងគំរោងតែម្តង។ ស្ថានភាពអាកាសធាតុនៅក្នុងតំបន់នេះមានការជួបប្រទះភាពរាំងស្ងួតច្រើន ដែលជាហេតុធ្វើឱ្យការ ដាំដុះដំណាំសណ្តែក និងស្រូវមិនសូវទទួលបាលទិន្នផលល្អច្រើនទេ។

តំបន់នេះសំបូរទៅដោយដីល្បាយក្រហម-ខ្មៅ ដែលជាប្រភេទដីមានជីវជាតិសំរាប់ដាំដំណាំនានា។ អាកាសធាតុមានសភាពប្រក្រតី ប៉ុន្តែនៅក្បែរតំបន់នេះ (ស្រុកអណ្តូងមាស) ធ្លាប់ទទួលរងនូវគ្រោះធម្មជាតិដូចជា ខ្យល់ព្យុះបាក់ផ្ទះ និងទឹកជំនន់កាលពីប៉ុន្មានឆ្នាំថ្មីៗនេះ។ ប្រព័ន្ធផ្លូវទឹកសំខាន់ៗរួមមាន អូរកប អូរប៉ក់ និងអូរចង្វារ។ ទោះបីជាយ៉ាងណា អូរចង្វារ និងដៃអូរផ្សេងៗទៀតទទួលរងនូវការគោកស្ងួតស្ទើរតែទាំងអស់នៅរដូវប្រាំង។ ប្រជាពលរដ្ឋប្រើប្រាស់ទឹកនៅក្នុងអូរទាំងនេះជាប្រចាំ ហើយក៏មិនធ្លាប់ដែលទទួលរងគ្រោះថ្នាក់ ឬពុលជាលក្ខណៈធ្ងន់ធ្ងរដែរ (ជួនកាលពុលចំណី ដោយសារបរិភោគត្រី ឬចំណីដែលទិញមកពីផ្សារ)។ ជំងឺគ្រុនចាញ់ ដែលជាជំងឺធ្លាប់កើតមានច្រើនចំពោះប្រជាពលរដ្ឋក្នុងតំបន់ បានថយចុះយ៉ាងខ្លាំងមកទល់បច្ចុប្បន្ន ប៉ុន្តែប្រជាពលរដ្ឋធ្លាប់

Draft

ទទួលរងនូវជំងឺពាក់ព័ន្ធនឹងផ្លូវដង្ហើម (របៀបថប់ៗដង្ហើម)។ មូលហេតុពិស្តារអំពីជំងឺនេះ មិនមានសិក្សាទេ។ ស្ថានភាពព្រៃឈើសព្វថ្ងៃ ស្ថិតជាព្រៃគុប ដែលមិនមានឈើមានតំលៃដូចជា ដើមបេង ដើមនាងនួន ដូចកាលពីសម័យមុនទៀតទេ លើកលែងតែឈើប្រភេទឈើទាល ស្រឡៅ កកោះ ដែលនៅមាន (ដើមធ្នុង អង្កត់ផ្ចិតតូចៗ អាចនៅមានខ្លះ)។ សត្វព្រៃធំៗក៏មិនមានទៀតដែរ។ បន្ថែមពីលើនេះទៀត នៅក្បែរទីតាំងគំរោងមានគំរោងអភិវឌ្ឍន៍ដំណាំកសិ-ឧស្សាហកម្មកៅស៊ូរបស់ក្រុមហ៊ុន ជា ម៉ន្នីរិទ្ធ ហើយគំរោងនេះធ្លាប់មានការប៉ះពាល់បញ្ហាដីធ្លីជាមួយប្រជាពលរដ្ឋដែរ។

- វត្តមានគំរោង: ពួកគាត់ធ្លាប់ដឹងលឺអំពីគំរោងអភិវឌ្ឍន៍របស់ក្រុមហ៊ុន ហើយក៏ធ្លាប់បានទៅដល់ទីស្នាក់ការរបស់ក្រុមហ៊ុនដែរ ក្នុងខណៈពេលបំពេញបេសកកម្មដោះស្រាយបញ្ហាប៉ះពាល់ដីធ្លី (ស្រែ-ចំការ ព្រៃអារក្សអ្នកតា ព្រៃសហគមន៍) រវាងក្រុមហ៊ុន និងប្រជាពលរដ្ឋ។ បញ្ហាទាំងនេះបានស្ងប់ស្ងាត់បន្ទាប់ពីបានធ្វើការដោះស្រាយ ដែលមានការចូលរួមពីសំណាក់ថ្នាក់ដឹកនាំក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អាជ្ញាធរដែនដី និងសហគមន៍មូលដ្ឋាន។ ពាក់ព័ន្ធនឹងគំរោងធ្វើអាជីវកម្មរ៉ែដែករបស់ក្រុមហ៊ុន ពួកគាត់មិនមានមតិជំទាស់ចំពោះគំរោងនេះទេ ព្រោះវាជាការសំរេចចិត្តរបស់រាជរដ្ឋាភិបាល ដែលមើលឃើញនូវការប្រើប្រាស់សក្តានុពលធនធានធម្មជាតិ (រ៉ែ) ដែលមានសំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។ ទោះជាយ៉ាងនេះក្តី លោកក៏បានលើកឡើងនូវការបារម្ភមួយចំនួនដូចខាងក្រោម:
  - បារម្ភ:
    - បារម្ភអំពីការប៉ះពាល់ដល់ដីធ្លីស្រែ-ចំការរបស់ប្រជាពលរដ្ឋនៅក្នុងភូមិកាចកប្រមាណ៥0%។
    - បារម្ភអំពីការប៉ះពាល់ទៅលើគុណភាពទឹកអូរប៉ក់ និងអូរទឹកផ្សេងៗទៀត។
    - បារម្ភអំពីការបាត់បង់ព្រៃឈើ។
    - បារម្ភអំពីការបំពុលខ្យល់ដែលអាចបង្កឡើងដោយសារការហុយធូលី មិនសូវមានទេ។
  - សំណូមពរ:
    - សូមឱ្យក្រុមហ៊ុនធ្វើសំណងដល់ប្រជាពលរដ្ឋដែលមានដីធ្លីស្រែ-ចំការប៉ះពាល់ ឱ្យបានត្រឹមត្រូវ និងអាចទទួលយកបាន។
    - សូមឱ្យក្រុមហ៊ុនធ្វើការសហការណ៏ឱ្យបានស្អិតរមួត ជាមួយប្រជាពលរដ្ឋ និងអាជ្ញាធរដែនដី និងរិះរកវិធី-សាស្ត្រដោះស្រាយបញ្ហាប៉ះពាល់នានាឱ្យបានល្អត្រឹមត្រូវ។
    - សូមឱ្យក្រុមហ៊ុនជួយផ្សព្វផ្សាយអំពីគំរោងដល់សហគមន៍មូលដ្ឋាន និងជូនដំណឹងដល់ប្រជាពលរដ្ឋ និងអាជ្ញាធរដែនដី នៅពេលចាប់ផ្តើមមានសកម្មភាពណាមួយ ដើម្បីចៀសវាងបញ្ហា ឬជំលោះផ្សេងៗកើតឡើង។

Draft

### ៥.២.១.៣. ការផ្សព្វផ្សាយ និងការជួបពិភាក្សាជាមួយអាជ្ញាធរ និងប្រជាពលរដ្ឋនៅក្នុងភូមិក្រៀល

ការផ្សព្វផ្សាយអំពីគំរោង និងការពិភាក្សាត្រូវបានធ្វើឡើងជាមួយលោកមេភូមិ អនុភូមិ សមាជិក និងប្រជាពលរដ្ឋមូលដ្ឋាន កាលពីថ្ងៃទី23 ខែវិច្ឆិកា ឆ្នាំ2010 នៅសាលាភូមិកក់ (រូបភាព29) ដើម្បីធ្វើការសាកសួរ ស្ទាបស្ទង់មតិ ជួបពិភាក្សា និងប្រមូលព័ត៌មានបន្ថែម ពីព្រោះភូមិនេះជាភូមិមួយមានប្រជាពលរដ្ឋរស់នៅ និងមានដីធ្លីស្រែ-ចំការនៅក្នុងទីតាំងគំរោង (ការរៀបរាប់ដូចមានខាងលើ មិនត្រូវបានលើកមកនិយាយម្តងទៀតទេ)។ ការពិគ្រោះយោបល់នេះបានបង្ហាញឱ្យឃើញថា ប្រជាពលរដ្ឋមានចំណាប់អារម្មណ៍ ការបារម្ភ និងសំណូមពរដូចខាងក្រោម៖

- ធ្លាប់មានការកាប់ឈើនៅក្នុងទីតាំងគំរោង ដើម្បីធ្វើការសិក្សាស្រាវជ្រាវរុករករ៉ែ និងដើម្បីធ្វើការសាងសង់ទីស្នាក់ការ និងទីស្នាក់នៅប្រមាណ១០ហ.ត.។
- ធ្លាប់មានការដោះស្រាយរបស់ក្រុមហ៊ុនអំពីបញ្ហាដែលធ្វើឱ្យប៉ះពាល់ដល់ដីធ្លីស្រែ-ចំការ និងទឹកអូរ (មិនបានដាក់លូត្រឹមត្រូវ ធ្វើឱ្យកប់អូរ ដែលជាហេតុធ្វើឱ្យប៉ះពាល់ដល់ការរកត្រី) របស់ប្រជាពលរដ្ឋមូលដ្ឋាន។
- បារម្ភអំពីការប៉ះពាល់ទៅលើដីធ្លីស្រែ-ចំការរបស់ប្រជាពលរដ្ឋ និងដីធ្លីសហគមន៍ និងដីធ្លីប្រពៃណី (ព្រៃអារក្ស-អ្នកតា រុក្ខជាតិថ្នាំបុរាណ អនុផលព្រៃឈើ) ដែលប្រជាពលរដ្ឋគោរពជាទីសក្ការៈសំរាប់ប្រារព្ធពិធីសែនព្រេនជាដើម។
- បារម្ភអំពីដំណោះស្រាយរបស់ក្រុមហ៊ុនចំពោះដីធ្លីដែលបំរុងទុកសំរាប់គ្រួសារកើតថ្មី (ជាធម្មតានៅពេលបែកគ្រួសារ ប្រជាពលរដ្ឋតែធ្វើការកាប់រានព្រៃបំរុងដើម្បីធ្វើជាកម្មសិទ្ធិ)។ ដោយហេតុថាដីធ្លីស្រែ-ចំការមានសារៈសំខាន់សំរាប់ការប្រកបរបរ និងចិញ្ចឹមជីវិតរបស់ពួកគាត់ ដូច្នេះក្នុងករណីនេះ តើក្រុមហ៊ុនអាចទុកដីធ្លីរបស់ពួកគាត់ឱ្យនៅដដែលបានឬទេ?
- បារម្ភខ្លាចក្រុមហ៊ុនស្នើសុំបន្ត ឬសុំអាជ្ញាប័ណ្ណថ្មី ដើម្បីប្តូរគំរោងអភិវឌ្ឍន៍របស់ខ្លួនពីការធ្វើអាជីវកម្មរ៉ែដែក ទៅជាគំរោងអភិវឌ្ឍន៍ផ្សេងទៀតដូចជា ដាំដំណាំកសិ-ឧស្សាហកម្ម (កៅស៊ូ)។
- បារម្ភអំពីការប៉ះពាល់ដល់គុណភាពទឹក ព្រោះប្រជាពលរដ្ឋត្រូវការទឹកសំរាប់ជីវភាពរស់នៅប្រចាំថ្ងៃ ក៏ដូចជាសេចក្តីត្រូវការរបស់រុក្ខជាតិ និងសត្វដែរ។
- បារម្ភអំពីការបំពុលដោយសំលេង-រំញ័រ និងបំពុលខ្យល់ដោយសារធូលី មិនមានខ្លាំងទេ ព្រោះទីតាំងគំរោងនៅឆ្ងាយពីតំបន់ភូមិករនៅឡើយ។
- សុំឱ្យក្រុមហ៊ុនសហការឱ្យបានល្អជាមួយប្រជាពលរដ្ឋមូលដ្ឋាន និងអាជ្ញាធរដែនដីដូចជា ការជូនដំណឹងដល់ពួកគាត់ មុននឹងចាប់ផ្តើមសកម្មភាពអនុវត្តន៍អ្វីមួយ។
- សុំឱ្យការវិនិយោគរបស់ក្រុមហ៊ុនផ្តល់ប្រយោជន៍ដល់ប្រជាពលរដ្ឋមូលដ្ឋាន និងចូលរួមអភិវឌ្ឍន៍សហគមន៍មូលដ្ឋានដូចជា ជួយអភិវឌ្ឍន៍ផ្លូវគមនាគមន៍ បណ្តាញចរន្តអគ្គិសនី និងបណ្តាញទឹកស្អាតជាដើម។

Draft

### ៥.២.១.៤. ការផ្សព្វផ្សាយ និងការជួបពិភាក្សាជាមួយអាជ្ញាធរ និងប្រជាពលរដ្ឋនៅក្នុងភូមិកាចក

ការផ្សព្វផ្សាយអំពីគំរោង និងការពិភាក្សាត្រូវបានធ្វើឡើងជាមួយលោកមេភូមិ អនុភូមិ សមាជិក និងប្រជាពលរដ្ឋមូលដ្ឋាន កាលពីថ្ងៃទី23 ខែវិច្ឆិកា ឆ្នាំ2010 នៅសាលាភូមិកក់ (រូបភាព29) ដើម្បីធ្វើការសាកសួរ ស្តាបស្ទង់មតិ ជួបពិភាក្សា និងប្រមូលព័ត៌មានបន្ថែម ពីព្រោះភូមិនេះជាភូមិមួយមានប្រជាពលរដ្ឋរស់នៅ និងមានដីធ្លីស្រែ-ចំការនៅក្នុងទីតាំងគំរោង (ការរៀបរាប់ដូចមានខាងលើ មិនត្រូវបានលើកមកនិយាយម្តងទៀតទេ) ។ ការពិគ្រោះយោបល់នេះបានបង្ហាញឱ្យឃើញថា៖

- ស្ថានភាពតំបន់ និងស្ថានភាពធម្មជាតិ-សង្គម៖ ភូមិកាចក ជាភូមិមួយស្ថិតនៅជាប់ផ្នែកខាងលិចពាយព្យនៃទីតាំងគំរោង ហើយក៏មានដីធ្លីស្រែ-ចំការរបស់ប្រជាពលរដ្ឋជាច្រើនស្ថិតនៅក្នុងទីតាំងគំរោង ។ ការតាំងទីលំនៅរបស់ប្រជាពលរដ្ឋ កើតមានតាំងពីសម័យមុនមកម្ល៉េះ ហើយពួកគាត់ប្រកបមុខរបរធ្វើកសិកម្មជាចំបង (ធ្វើចំការ ធ្វើស្រូវទាំងលក្ខណៈអចិន្ត្រៃយ៍ និងពនេចរ) ជាមួយនឹងមុខរបរបន្ទាប់បន្សំ ដូចជា ចិញ្ចឹមសត្វ ចាប់ត្រីតាមអូរ-ត្រពាំង និងការដាក់អន្ទាក់ចាប់សត្វព្រៃជាដើម ។ មនុស្សចាស់ និងក្មេងនៅក្នុងភូមិនេះធ្លាប់មានបញ្ហារបួសម្រាមដៃ-ជើង ដែលទាំងនេះអាចពាក់ព័ន្ធនឹងថ្នាំគីមី ដែលបានប្រើប្រាស់ ឬបាញ់ភាយនៅក្នុងកន្លែងណាមួយ ។ ទោះបីជាយ៉ាងណា ការសិក្សាដើម្បីរកឱ្យឃើញមូលហេតុនេះមិនត្រូវបានធ្វើឡើងទេ ។ បញ្ហាសុខភាពផ្សេងទៀតដែលកើតមានរួមមាន គ្រុនរងារ គ្រុនផ្តាសសាយ ឈឺក្បាល ចុកពោះ គ្រុនពោះវៀន រលាកបំពង់ក (កើតមានច្រើនចំពោះក្មេងៗក្នុងរយៈពេល02–03ឆ្នាំថ្មីៗនេះ) ។

ប្រជាពលរដ្ឋក្នុងកំឡុងពេលប៉ុន្មានឆ្នាំថ្មីៗនេះមានការកើនឡើង ប៉ុន្តែកំនើនប្រជាពលរដ្ឋចំណាកស្រុកមិនមានទេ ។ គួរកត់សំគាល់ផងដែរថា ភូមិកាចក គឺជាភូមិមួយនៅក្បែរទីតាំងគំរោង ហើយប្រជាពលរដ្ឋមួយចំនួនធំ (ប្រមាណ80%នៃប្រជាពលរដ្ឋក្នុងភូមិសរុប) មានដីធ្លីស្រែ-ចំការនៅក្នុងទីតាំងគំរោងតែម្តង ។ ស្ថានភាពអាកាសធាតុនៅក្នុងតំបន់នេះមានការជួបប្រទះភាពរាំងស្ងួតច្រើន ដែលជាហេតុធ្វើឱ្យការដាំដុះដំណាំសណ្តែក និងស្រូវមិនសូវទទួលបានទិន្នផលល្អច្រើនទេ ។ ប្រជាពលរដ្ឋរស់នៅក្នុងតំបន់នេះភាគច្រើនធ្វើចំការ និងដាំដំណាំ (ដំឡូង សណ្តែក ស្រូវ) ជាចំបង និងមុខរបរបន្ទាប់បន្សំមានដូចជា កាប់ឈើ បរបាញ់ បំរើសេវាកម្ម (ធ្វើជាកម្មករ) ធ្វើអាជីវកម្ម និងប្រមូលអនុផលព្រៃឈើជាដើម ។ ស្ថានភាពព្រៃឈើស្ថិតក្នុងសភាពថយចុះយ៉ាងខ្លាំង (ជាពិសេសចាប់តាំងពីឆ្នាំ2000) ដោយសារតែសកម្មភាពកាប់ឈើជាលក្ខណៈអនាធិបតេយ្យ និងការធ្វើស្រែ-ចំការជាលក្ខណៈពនេចរ ។ សត្វព្រៃក៏បាន បាត់បង់យ៉ាងខ្លាំងដែរ ដោយសារការបាត់បង់ទីជំរក និងការបរបាញ់ ។

ប្រជាពលរដ្ឋប្រើប្រាស់ទឹកដោយពឹងផ្អែកស្ទើរតែទាំងស្រុងទៅលើទឹក ដែលមានប្រភពមកពីទឹកភ្លៀង និងទឹកនៅក្នុងអូរកប (មានទឹកពេញមួយឆ្នាំ ហើយច្រើន ឬតិចទៅតាមរដូវ និងភ្លៀងធ្លាក់) ។ ប្រជាពលរដ្ឋក៏បានប្រើ-ប្រាស់ទឹកដែលកេនអូរកប និងអូរប៉ប៉ដែរ ប៉ុន្តែទឹកនៅក្នុងអូរនេះភាគច្រើនទទួលរងនូវការគោករីងស្ងួត ។ គួរ-

កត់សំគាល់ផងដែរថា ទោះបីជាមិនមានប្រភពច្បាស់លាស់ ពួកគាត់ធ្លាប់ត្រូវបានគេ (អង្គការ និងមន្ត្រីថ្នាក់លើរាជរដ្ឋាភិបាល) ប្រាប់ឱ្យដឹងថាមានគំរោងបំរុងដីទុកសំរាប់ប្រជាពលរដ្ឋ។

- វត្តមានគំរោង: ពួកគាត់បានដឹងលឺយ៉ាងច្បាស់អំពីគំរោងអភិវឌ្ឍន៍របស់ក្រុមហ៊ុន ព្រោះគំរោងនេះបានធ្វើឱ្យប៉ះពាល់ដល់ពួកគាត់ ហើយជាមួយគ្នានេះដែរ ពួកគាត់បានលើកឡើងនូវចំណាប់អារម្មណ៏ ការបារម្ភ និងសំណូមពរដូចតទៅ:
  - ចំណាប់អារម្មណ៏ និងបារម្ភ:
    - បារម្ភអំពីការប៉ះពាល់ដីធ្លី (ស្រែ-ចំការ ព្រៃលិចទឹក) ទាំងលក្ខណះអចិន្ត្រៃយ៏ និងពនេចរ។
    - បារម្ភអំពីការបាត់បង់ការងារ (ក្រុមហ៊ុនបានបញ្ឈប់ការងារប្រជាពលរដ្ឋមួយចំនួនពីគំរោង ដោយមិនបានជូនដំណឹងទុកជាមុន)។
    - បារម្ភដោយមិនដឹងថាហេតុអ្វីបានជាក្រុមហ៊ុនបាញ់ថ្នាំក្របាមតាមដើមឈើ និងកន្លែងផ្សេងៗនៅក្នុងដីធ្លីស្រែ-ចំការរបស់ ពួកគាត់។
    - បារម្ភអំពីការប៉ះពាល់ដល់គុណភាពដី ដែលក្លាយទៅជាគ្មានជីជាតិបន្ទាប់ពីដីស្រទាប់លើត្រូវបានកាយចេញ ហើយដីដែលលុបមកវិញមិនអាចធ្វើការដាំដុះបាន។
    - បារម្ភអំពីដំណោះស្រាយរបស់ក្រុមហ៊ុន ចំពោះផលដំណាំ និងដើមឈើដែលមានអាយុ និងផ្តល់ទិន្នផលច្រើននៅក្នុងដីធ្លីរបស់ពួកគាត់។
    - បារម្ភអំពីការបាត់បង់ព្រៃបំរុង ដែលជាទីជំរករបស់សត្វ និងជាទីសក្ការៈបូជា (អារក្ស-អ្នកតា) របស់ប្រជាពលរដ្ឋ។
    - ក្រុមហ៊ុនមិនបានជូនដំណឹងដល់ប្រជាពលរដ្ឋអំពីសកម្មភាពរបស់ខ្លួនដូចជាកាប់រានព្រៃ និងចំការ ដើម្បីធ្វើការសិក្សាស្រាវជ្រាវរុករករ៉ែជាដើម។
    - នៅពេលបំរើការងារជូនក្រុមហ៊ុន គឺប្រជាពលរដ្ឋធ្វើការតាមការបញ្ជារបស់ក្រុមហ៊ុនដូចជា ឱ្យកាប់ឈើ ហើយនៅពេលដែលឈើនោះដួលរលំលើចំការអ្នកស្រុក ក្រុមហ៊ុនសន្យាថានឹងធ្វើសំណង ប៉ុន្តែក្រុមហ៊ុនមិនបានធ្វើទេ។
    - មានការប៉ះពាល់ដល់សតិអារម្មណ៏ប្រជាពលរដ្ឋមូលដ្ឋាន និងបុគ្គលិក-កម្មករ (ធ្វើការងារដោយប្រកាន់ពូជសាសន៏ជាដើម)។
  - សំណូមពរ:
    - សូមឱ្យក្រុមហ៊ុនជូនដំណឹង និងសហការស្និតរមួតជាមួយប្រជាពលរដ្ឋមូលដ្ឋាន អាជ្ញាធរដែនដី និងរាជរដ្ឋាភិបាល (ជូន ដំណឹងនៅពេលដែលត្រូវការដីរបស់ប្រជាពលរដ្ឋ និងភូមិ)។

Draft

- ○ សូមឱ្យក្រុមហ៊ុនធ្វើការតាមច្បាប់ និងស្របច្បាប់ ។
- ○ សូមឱ្យក្រុមហ៊ុនជូនដំណឹង និងពន្យល់ដល់បុគ្គលិក-កម្មករអំពីមូលហេតុនៃការបញ្ឈប់ការងារ ។

### ៥.២.២. ការផ្សព្វផ្សាយអំពីគំរោង និងការជួបពិគ្រោះយោបល់ជាមួយអាជ្ញាធរស្រុកអូរយ៉ាដាវ

ការជួបសំភាសន៏ និងពិគ្រោះយោបល់ជាមួយ**លោក ដក ស** (អភិបាលស្រុក) និង**លោក កប សារឿន** (អភិបាលរងស្រុក) កាលពីថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ2010 នៅសាលាស្រុកអូរយ៉ាដាវ (រូបភាព23) ត្រូវបានធ្វើឡើង ដើម្បីសាកសួរ និងប្រមូលព័តិមានបន្ថែម (គួរកត់សំគាល់ផងដែរថា ការរៀបរាប់មានដូចខាងលើ មិនត្រូវបានលើកមកនិយាយម្តងទៀតទេ)៖

- ❖ ប្រជាសាស្ត្រ និងការតាំងទីលំនៅរបស់ប្រជាពលរដ្ឋ៖ ប្រជាពលរដ្ឋដែលមកតាំងទីលំនៅក្នុងស្រុកអូរយ៉ាដាវ កើតមានចាប់តាំងពីយូរឆ្នាំមកហើយ ដែលនៅពេលនោះប្រជាពលរដ្ឋភាគច្រើនជាជនជាតិដើមភាគតិច ។ ក្រោយមកចំនួនប្រជាពលរដ្ឋទាំងនេះមានការកើនឡើងជាបន្តបន្ទាប់ រួមជាមួយនឹងកំនើនចំនួនប្រជាពលរដ្ឋចំណាកស្រុកមកពីតំបន់ផ្សេងៗទៀតផងដែរ ដែលរួមមានទាំងប្រជាពលរដ្ឋជនជាតិខ្មែរ និងខ្មែរ-អ៊ីស្លាម ហើយមកទល់បច្ចុប្បន្នប្រជាពលរដ្ឋមានចំនួនរហូតដល់ប្រមាណជាង3.200គ្រួសារ (ស្មើនឹងប្រមាណ15.400នាក់) ។ ភាគច្រើននៃប្រជាពលរដ្ឋទាំងនេះ គឺរស់នៅតាមបណ្តោយផ្លូវជាតិ និងផ្លូវលំផ្សេងៗនៅក្នុងភូមិ-ឃុំ ។ ការកើនឡើងនូវចំនួនប្រជាពលរដ្ឋទាំងនេះ គឺដោយសារមានការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចដូចជា វត្តមានផ្លូវជាតិ-ផ្លូវលំល្អ និងប្រភេទដីមានជីវជាតិជាច្រើន ដែលផ្តល់ការងាយស្រួលដល់ពួកគាត់ក្នុងការប្រកបមុខរបរផ្សេងៗ ។
- ❖ ស្ថានភាពសង្គម៖ ប្រជាពលរដ្ឋនៅក្នុងតំបន់ស្រុកអូរយ៉ាដាវ ភាគច្រើនប្រកបមុខរបរ ធ្វើចំការ (ប្រមាណ80%) ដាំដំណាំ និងបន្លែ (ដំឡូង សណ្តែក ពោត ស្វាយចាន់ទី៖ គ្រួសារខ្លះមានដីរហូតដល់ទំហំ 02–2,50ហ.ត./គ្រួសារ) ក្នុងរយៈពេលពេញមួយឆ្នាំ និងមុខរបរបន្ទាប់បន្សំផ្សេងទៀតដូចជា កាប់ឈើ បរបាញ់ ចាប់ត្រី បំរើសេវាកម្ម (ធ្វើជាកម្មករ) ធ្វើអាជីវកម្ម និងប្រមូលអនុផលព្រៃឈើ (ដងជ័រឈើ) ។ ប្រជាពលរដ្ឋទាំងនេះប្រើប្រាស់ទឹកដោយពឹងផ្អែកស្ទើរតែទាំងស្រុងទៅលើទឹកដែលមានប្រភពមកពីទឹកភ្លៀង (ជាពិសេសសំរាប់ធ្វើស្រែ-ចំការ និងដាំដំណាំ) ទឹកតាមដងអូរ និងអណ្តូងទឹកច្រប់ ។ គួរកត់សំគាល់ផងដែរថា ទោះបីជាមានអណ្តូងស្នប់នៅតាមភូមិ-ឃុំក៏ដោយ ក៏ពួកគាត់និយមប្រើប្រាស់អណ្តូងទឹកច្រប់សំរាប់គេហដ្ឋានដូចជា សំរាប់បរិភោគ និងដាំស្លជាដើម ។ គុណភាពទឹកមិនធ្លាប់មានការបំពុលទេមកទល់បច្ចុប្បន្ន លើកលែងតែការពុលចំណីអាហារដែលបង្កឡើងដោយការបរិភោគបន្លែទិញមកពីផ្សារ ។ បណ្តាញចរន្តអគ្គិសនីពុំទាន់មានទេ ប៉ុន្តែប្រជាពលរដ្ឋប្រើប្រាស់ភ្លើងអាគុយសំរាប់ការបំភ្លឺ ចំណែកឯថាមពលប្រើប្រាស់សំរាប់ចំអិនអាហារវិញ បានមកពីការរើសឈើ ឬកាប់ឈើមួយចំនួននៅក្នុង និងក្បែរតំបន់ ។

Draft

ម៉្យាងទៀត ទោះបីជានៅក្នុងស្រុកពុំមានសាលារៀនច្រើនគ្រប់គ្រាន់ក៏ដោយ ក៏ភាគច្រើននៃប្រជាពលរដ្ឋបានចូលរៀន ហើយខ្លះបន្តការសិក្សាថ្នាក់ឧត្តមសិក្សានៅទីរួមខេត្តទៀតផង (ចំនួនតិចតួចបំផុត: ប្រមាណ03–04 នាក់)។ បញ្ហាសុខភាពដែលកើតមានរួមមាន គ្រុនផ្តាសាយ គ្រុនឈាម គ្រុនចាញ់ (តិចតួច) និងរោគស្ត្រី (ជាពិសេសផ្នែកសម្ភព ប៉ុន្តែបច្ចុប្បន្នអត្រាគ្រោះថ្នាក់ធ្ងន់ធ្ងរបានថយចុះ ដោយសារមានការអប់រំពីបណ្តាអង្គការ និងស្ថាប័នពាក់ព័ន្ធ)។ ជាទូទៅពួកគាត់តែងធ្វើការព្យាបាលជំងឺដោយចូលសំរាកព្យាបាលនៅក្នុងពេទ្យឯកជន និងរដ្ឋ ចំណែកឯការប្រើប្រាស់ឱសថបុរាណនៅមានខ្លះៗដែរ។ ក្នុងករណីស្ថានភាពជំងឺពុំបានធូរស្បើយ ពួកគាត់ធ្វើការបន់ស្រន់ និងសែនព្រេនអារក្ស-អ្នកតាតាមប្រពៃណី និងទំលៀមទំលាប់ពីបុរាណរបស់ពួកគាត់។ ចំពោះបងប្អូនជនជាតិដើមភាគតិច ពួកគាត់មានការជួយគ្នាណាស់ក្នុងការព្យាបាលជំងឺដូចជា ឱ្យខ្ចីលុយ និងចែកចំណីអាហារគ្នាជាដើម។ សម្បត្តិវប្បធម៌ ឬសំណង់បុរាណពុំមានទេ លើកលែងតែបងប្អូនជនជាតិដើមភាគតិចទំពួន និងចារាយដែលពួកគាត់នៅគោរពបូជាចំពោះទីសក្ការៈដូចជា ព្រៃ ដើមឈើ ឬថ្មប៉ុណ្ណោះ (ទីតាំងមិនកំណត់ច្បាស់លាស់)។

- ស្ថានភាពតំបន់ និងបរិស្ថាន-ធម្មជាតិ: ស្រុកអូរយ៉ាដាវ មានអំណោយផលផ្នែកធម្មជាតិដូចជា ដីល្បាយក្រហម-ខ្មៅដែលប្រភេទដីមានជីវជាតិសំរាប់ការដាំដុះដំណាំផ្សេងៗ ហើយពុំធ្លាប់កើតមាននូវគ្រោះមហន្តរាយធម្មជាតិដូចជា ខ្យល់ព្យុះ ឬទឹកជំនន់ឡើយ លើកលែងតែអាកាសធាតុដែលធ្លាប់កើតមានភាពរាំងស្ងួតមួយចំនួន។ តំបន់នេះមានប្រព័ន្ធផ្លូវទឹកមួយចំនួនដូចជា ទឹកអូរ ទឹកជ្រលងអូរ ដែលមានតែមួយចំនួនប៉ុណ្ណោះមានទឹកខួបប្រាំង-វស្សា។ ស្ថានភាពព្រៃឈើកាលពីជំនាន់មុនៗ គឺមានដើមឈើល្អៗ និងមានតំលៃច្រើន ប៉ុន្តែឆ្លងកាត់សម័យជាច្រើនមកទល់បច្ចុប្បន្ន ស្ថានភាពព្រៃឈើទាំងនេះមានការប្រែប្រួលច្រើនហើយភាគច្រើននៃឈើល្អៗក៏បានបាត់បង់ដែរ។ ការប្រែប្រួលនេះបណ្តាលមកពីកត្តាជាច្រើនដូចជា ការកាប់ព្រៃ (ជាពិសេសការកាប់ឈើខុសច្បាប់) ការរានព្រៃធ្វើស្រែ-ចំការជាលក្ខណៈអចិន្ត្រៃយ៍ ឬពនេចរជាដើម។ ចំណែកឯស្ថានភាពសត្វព្រៃវិញ ក៏មានទំនោរស្របគ្នានឹងស្ថានភាពព្រៃឈើដែរ។ សត្វព្រៃសំខាន់ៗមួយចំនួនធំត្រូវបានបាត់បង់ ហើយសត្វដែលនៅមានជួបប្រទះដូចជា សត្វឈ្លូស ប្រម៉ា ទន្សាយ ជ្រូកព្រៃ ក៏ទទួលរងនូវការគំរាមកំហែងខ្លាំងក្លាដែរ ដោយសារសកម្មភាពបរបាញ់ និងដាក់អន្ទាក់ស្ទើរគ្រប់ទីកន្លែងពីសំណាក់ជនខិលខូច ។
- ការពិគ្រោះយោបល់ និងពិភាក្សានេះក៏បានបង្ហាញឱ្យឃើញផងដែរថា ពួកគាត់ធ្លាប់បានដឹងលឺអំពីគំរោងអភិវឌ្ឍន៍ និងតំបន់ស្នើសុំធ្វើអាជីវកម្មរ៉ែរបស់ក្រុមហ៊ុន ដោយសារពួកគាត់ធ្លាប់ចូលរួមសហការជាមួយស្ថាប័នពាក់ព័ន្ធផ្សេងៗទៀតក្នុងការដោះស្រាយបញ្ហាប៉ះពាល់ដីធ្លីស្រែ-ចំការរបស់ប្រជាពលរដ្ឋកន្លងមក ដែលក្នុងនោះមានការចូលរួមពីសំណាក់**ឯកឧត្តម ស៊ុយ សែម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល** ផងដែរ។ នៅក្នុងពេលនោះ ក៏មានការចែកអង្ករ និងអំណោយសំភារៈប្រើប្រាស់ផ្សេងៗដល់ប្រជាពលរដ្ឋ។ ពួកគាត់ខ្លះពុំព្រមទទួលយកអំណោយទាំងនោះទេ ប៉ុន្តែក្រោយមកទើបព្រមទទួលយក ដោយសារក្រុមហ៊ុនបានបង្ហាញអំពីនីតិវិធីដោះស្រាយលើបញ្ហាប៉ះ-

Draft

ពាល់ដីធ្លីទាំងនោះ ដោយទទួលសងជាទឹកប្រាក់ទ្វេរដង ទៅលើទិន្នផល (ផលកំរៃ) ដែលប្រជាពលរដ្ឋម្ចាស់ដីធ្លីទទួលបានពីការដាំដុះពេញមួយឆ្នាំនៅក្នុងដីធ្លីរបស់ពួកគាត់ ។ បន្ទាប់ពីបានដោះស្រាយបញ្ហាទាំងនេះរួមគ្នាមក ការសហការរវាងអាជ្ញាធរដែនដី និងក្រុមហ៊ុនបានល្អឡើង ហើយប្រជាពលរដ្ឋក៏មានសេចក្តីត្រេកអរផងដែរ នៅពេលដែលបានដឹងលឺថា ពួកគាត់នឹងត្រូវបានជ្រើសរើសឱ្យចូលបំរើការងារនៅពេលដែលក្រុមហ៊ុនដំណើរការអាជីវកម្ម ។ ជាមតិរបស់អាជ្ញាធរដែនដី ពួកគាត់ក៏ពុំមានមតិជំទាស់ចំពោះវត្តមានក្រុមហ៊ុនមកធ្វើការអភិវឌ្ឍន៍នៅក្នុងតំបន់នេះទេ ព្រោះពួកគាត់ក៏បានដឹងដែរថា វាជាការសំរេចចិត្តរបស់រាជរដ្ឋាភិបាល ។ ទន្ទឹមនឹងនេះដែរ ពួកគាត់បានលើកឡើងនូវចំណាប់អារម្មណ៍ និងសំណូមពរមួយចំនួនដូចតទៅ:

- ចំណាប់អារម្មណ៍:
  - បារម្ភទៅលើការសហការគ្នារវាងអាជ្ញាធរដែនដី ប្រជាពលរដ្ឋ និងក្រុមហ៊ុន ព្រោះបញ្ហាកើតមានកន្លងមកបណ្តាលមកពីការខ្វះការសហការគ្នា ។
  - បារម្ភទៅលើការសំរបសំរួលជាមួយប្រជាពលរដ្ឋ ព្រោះប្រជាពលរដ្ឋនីមួយៗខុសៗគ្នាដែលមួយចំនួនអាចងាយស្រួលក្នុងការជឿជាក់លើការបកស្រាយ ឬបញ្ចុះបញ្ចូលពីភាគីខាងក្រៅ (ឧ. អង្គការ ឬប្រើឈ្មោះជាអង្គការ) និងបង្កឱ្យកើតមានបញ្ហាផ្សេងៗដោយសារខ្វះការសហការគ្នា និងដោយសារប្រជា-ពលរដ្ឋពុំបានយល់ដឹងច្បាស់អំពីច្បាប់ ។
  - បារម្ភខ្លាចបាត់បង់ការរកអនុផលព្រៃឈើ និងការចាប់ត្រីរបស់ប្រជាពលរដ្ឋ ។
  - បារម្ភអំពីការជាន់ទីតាំងជាមួយក្រុមហ៊ុនអភិវឌ្ឍន៍ផ្សេងទៀតដូចជា គំរោងអភិវឌ្ឍន៍ដីសម្បទានសេដ្ឋ-កិច្ចរបស់ក្រុមហ៊ុន ជា ច័ន្ទរិទ្ធ ជាដើម ។
  - មិនមានការបារម្ភធ្ងន់ធ្ងរអំពីការបំពុលទឹកនោះទេ ព្រោះស្ថានភាពទឹកហូរ គឺហូរចុះទៅតំបន់ខាងក្រោម (មិនមែនស្រុកអូរយ៉ាដាវទេ) ។
- សំណូមពរ:
  - សូមឱ្យក្រុមហ៊ុនសហការជាមួយអាជ្ញាធរដែនដី ក៏ដូចជាជាមួយប្រជាពលរដ្ឋ ឱ្យបានស្អិតរមួត ដើម្បីរួមគ្នាដោះស្រាយបញ្ហាផ្សេងៗកើតឡើង ។
  - សូមឱ្យធ្វើការពិគ្រោះយោបល់ជាមួយរដ្ឋបាលព្រៃឈើ ដើម្បីក្តាប់ឱ្យបាននូវព័ត៌មានទាក់ទងនឹងការកាប់ព្រៃឈើដោយមាន ឬគ្មានការអនុញ្ញាតិដែលការកាប់ព្រៃឈើមួយចំនួនអាចប៉ះពាល់ដល់ប្រជាពលរដ្ឋ ។

Draft

### ៥.២.២.១. ការផ្សព្វផ្សាយអំពីគំរោង និងការពិគ្រោះយោបល់ជាមួយអាជ្ញាធរឃុំឈើវែរ

ការផ្សព្វផ្សាយអំពីគំរោង និងការពិគ្រោះយោបល់ជាមួយ**លោក សេវ ថ្វាន** (មេឃុំ) និងលោកជំទប់ និងសមាជិកឃុំ កាលពីថ្ងៃទី20 ខែវិច្ឆិកា ឆ្នាំ2010 (រូបភាព29) ត្រូវបានធ្វើឡើង ដើម្បីសាកសួរ និងប្រមូលព័ត៌មានបន្ថែម (ផ្តោតសំខាន់ទៅលើភូមិដែលនៅក្បែរទីតាំងគំរោង ហើយការរៀបរាប់ដូចមានខាងលើ មិនត្រូវបានលើកមកនិយាយម្តងទៀតទេ):

- ស្ថានភាពតំបន់ និងស្ថានភាពធម្មជាតិ-សង្គម: ប្រជាពលរដ្ឋមកតាំងទីលំនៅនៅក្នុងតំបន់នេះ កើតមានចាប់តាំងពីមុនសម័យសម្តេចឪ ក្នុងទសវត្ស1950មកម្ល៉េះ ហើយបន្តរស់នៅរហូតមកដល់បច្ចុប្បន្ន។ ភូមិដែលនៅក្បែរទីតាំងគំរោង គឺភូមិប្រឡេ ដែលប្រជាពលរដ្ឋមួយចំនួនធំមានដីធ្លីស្រែ-ចំការនៅក្នុងទីតាំងគំរោង។ ស្ថានភាពព្រៃឈើនៅក្នុងតំបន់នេះទទួលរងនូវការប្រែក្លាយជាច្រើន ហើយវត្តមានដើមឈើមានតំលៃ (ប្រភេទបេង នាងនួន ធ្នុង) មិនសូវឃើញមានទៀតទេនៅពេលបច្ចុប្បន្ន លើកលែងតែដើមឈើប្រភេទស្រឡៅ ឈើទាល សុក្រមជាដើម។ ការបាត់បង់នូវឈើមានតំលៃទាំងនេះ ដោយសារការកាប់យកទៅលក់ពីសំណាក់ប្រជាពលរដ្ឋ និងជាពិសេសដោយសារការកាប់ខុសច្បាប់របស់ជនខិលខូច។ សត្វព្រៃដែលនៅជួបប្រទះរួមមាន សត្វប្រើស ឈ្លូស ខ្លាឃ្មុំ (មិនងាយឃើញ) ចំណែកសត្វថ្នាក់ធំៗដូចជា សត្វខ្លា និងដំរី មិនមានទេ។
- វត្តមានគំរោង: លោកធ្លាប់ដឹងលឺអំពីគំរោងធ្វើអាជីវកម្មរ៉ែរបស់ក្រុមហ៊ុន ដែលស្ថិតនៅក្បែរភូមិ-ឃុំរបស់គាត់ ហើយលោកក៏បានដឹងលឺអំពីបញ្ហាប៉ះពាល់លើដីធ្លីស្រែ-ចំការ និងបញ្ហាផ្សេងៗទៀតពាក់ព័ន្ធនឹងការខ្វះការសហការរវាងក្រុមហ៊ុននឹងអាជ្ញាធរដែនដី និងប្រជាពលរដ្ឋដូចជា ការមិនជូនដំណឹងដល់ពួកគាត់នៅពេលចំណុចសិក្សាស្រាវ-ជ្រាវរុករករ៉ែ (បាញ់ថ្នាំក្រហមតាមដើមឈើ វានដីសំរាប់ទីតាំងចំណុចសិក្សាជាដើម)។ ទន្ទឹមនឹងនេះដែរ លោកបានលើកឡើងនូវក្តីបារម្ភ និងសំណូមពរដូចតទៅ:
  - ការបារម្ភ:
    - បារម្ភទៅលើការប៉ះពាល់ដល់ដីធ្លីស្រែ-ចំការអចិន្ត្រៃយ៍ និងពនេចររបស់ប្រជាពលរដ្ឋ ដែលមាននៅក្នុងទីតាំងគំរោងរបស់ក្រុមហ៊ុន និងខ្លាចមានការគំរាមគំហែងពីសំណាក់ជនផ្សេងៗ។
    - បារម្ភទៅលើការប៉ះពាល់ដល់ព្រៃសហគមន៍ភូមិប្រឡេ (មិនទាន់ចេញជាផ្លូវការ ប៉ុន្តែស្ថិតនៅក្នុងស្ថានភាពជាគំរោងរបស់ខ័ណ្ឌរដ្ឋបាលព្រៃឈើ) និងព្រៃឈើ ឬថ្មធំៗមួយចំនួនដែលជាទីសក្ការៈបូជា ឬបន់ស្រន់របស់ប្រជាពលរដ្ឋតាំងពីយូរយារណាស់មកហើយ (ទិតាំងមិនកំណត់ច្បាស់លាស់)។
    - បារម្ភខ្លាចប៉ះពាល់ដល់ទីសក្ការៈបូជារបស់ជនជាតិនៅក្នុងតំបន់ភ្នំទ្រូ និងភ្នំដូង ប៉ុន្តែលោកមិនទាន់អាចបញ្ជាក់បានច្បាស់លាស់អំពីចំណុច ឬទីតាំងពិតប្រាកដនៅឡើយទេ។ ក្នុងករណីប្រសិនបើការសិក្សាបាន

Draft

បង្ហាញថា ចំណុច ឬទីតាំងសក្ការៈបូជាភ្នំទ្រូ និងភ្នំដូង មានសក្តានុពលធនធានរ៉ែ តើអាចចៀសមិនធ្វើអាជីវកម្មរ៉ែបានដែរ ឬអត់។

- ○ បារម្ភទៅលើការបំពុលទឹកដែលជាប្រភពសំរាប់ប្រជាពលរដ្ឋ ព្រោះសកម្មភាពអាជីវកម្មរ៉ែ យ៉ាងហោចណាស់ក៏អាចមានប្រើប្រាស់សារធាតុគីមីគ្រោះថ្នាក់បន្តិចបន្តួច។

- សំណូមពរៈ
  - ○ សូមឱ្យធ្វើការពិចារណារកលទ្ធភាពទុក ឬកាត់ក្បៀងដី ដែលជាទីសក្ការៈបូជារបស់ប្រជាពលរដ្ឋ ទោះបីជាដីនេះមានសក្តានុពលធនធានរ៉ែក៏ដោយ ហើយក្នុងករណីដែលមិនត្រូវការសំណង។
  - ○ សូមឱ្យក្រុមហ៊ុនដោះស្រាយបញ្ហាប៉ះពាល់ដីធ្លីស្រែ-ចំការរបស់ប្រជាពលរដ្ឋ ឱ្យបានល្អ និងសមស្របអាចទទួលយកបាន។

### ៥.២.២.២. ការផ្សព្វផ្សាយអំពីគំរោង និងការជួបពិគ្រោះយោបល់ជាមួយអាជ្ញាធរឃុំសោមធំ

ការផ្សព្វផ្សាយអំពីគំរោង និងការពិគ្រោះយោបល់ជាមួយ**លោក សល់ តួន** (មេឃុំ) កាលពីថ្ងៃទី20 ខែវិច្ឆិកា ឆ្នាំ2010 (រូបភាព29) ត្រូវបានធ្វើឡើង ដើម្បីសាកសួរ និងប្រមូលព័ត៌មានបន្ថែម (ផ្តោតសំខាន់ទៅលើភូមិដែលនៅក្បែរទីតាំងគំរោង ហើយការរៀបរាប់ដូចមានខាងលើ មិនត្រូវបានលើកមកនិយាយម្តងទៀតទេ)។ លោកធ្លាប់បានដឹងលឺអំពីគំរោងអភិវឌ្ឍន៍ដំណាំកសិ-ឧស្សាហកម្មកៅស៊ូរបស់ក្រុមហ៊ុន ជា ច័ន្ទរិទ្ធ ប៉ុន្តែលោកមិនបានដឹងលឺអំពីវត្តមានគំរោងធ្វើអាជីវកម្មរ៉ែរបស់ក្រុមហ៊ុនទេ។ ដោយហេតុនេះហើយ ស្ថានភាពទូទៅ និងការប៉ះពាល់ផ្សេងៗពាក់ព័ន្ធនឹងគំរោងរបស់ក្រុមហ៊ុន គឺលោកមិនបានដឹងទេ។ ទោះបីជាយ៉ាងនេះក្តី លោកបានសំណូមពរឱ្យក្រុមហ៊ុនសហការជាមួយអាជ្ញាធរដែនដីឃុំឱ្យបានល្អ ដើម្បីតាមដានការងារផ្សេងៗពាក់ព័ន្ធនឹងដំណើរការ និងការវិវត្តន៍នៃគំរោង។

### ៥.២.២.៣. ការផ្សព្វផ្សាយ និងការជួបពិភាក្សាជាមួយអាជ្ញាធរ និងប្រជាពលរដ្ឋនៅក្នុងភូមិប្រទៀ

ការផ្សព្វផ្សាយអំពីគំរោង និងការពិភាក្សាត្រូវបានធ្វើឡើងជាមួយលោកមេភូមិ អនុភូមិ សមាជិក និងប្រជាពលរដ្ឋមូលដ្ឋាន កាលពីថ្ងៃទី23 ខែវិច្ឆិកា ឆ្នាំ2010 នៅសាលាភូមិកក់ (រូបភាព29) ដើម្បីធ្វើការសាកសួរ ស្ទាបស្ទង់មតិ ជួបពិភាក្សា និងប្រមូលព័ត៌មានបន្ថែម ពីព្រោះភូមិនេះជាភូមិមួយមានប្រជាពលរដ្ឋរស់នៅ និងមានដីធ្លីស្រែ-ចំការនៅក្នុងទីតាំងគំរោង (ការរៀបរាប់ដូចមានខាងលើ មិនត្រូវបានលើកមកនិយាយម្តងទៀតទេ)។ ការពិគ្រោះយោបល់បានបង្ហាញឱ្យឃើញថា ថ្នាក់ឃុំ-ស្រុកបានដឹងលឺអំពីគំរោងសិក្សាស្រាវជ្រាវរុករករ៉ែ និងគំរោងធ្វើអាជីវកម្មរ៉ែដែករបស់ក្រុមហ៊ុន ប៉ុន្តែប្រជាពលរដ្ឋមូលដ្ឋានមិនធ្លាប់បានដឹងលឺអំពីគំរោងទាំងនេះទេ។ ការពិគ្រោះយោបល់នេះបានបង្ហាញឱ្យឃើញថា ប្រជាពលរដ្ឋមានចំណាប់អារម្មណ៍ ការបារម្ភ និងសំណូមពរដូចខាងក្រោមៈ

- ចំណាប់អារម្មណ៍ និងការបារម្ភៈ
    - បារម្ភអំពីការប៉ះពាល់ព្រៃតំបន់ការពារសហគមន៍ (ព្រៃអារក្ស-អ្នកតា) និងអំពីការបាត់បង់ប្រភេទឈើ-វប្បធម៌ក្នុងតំបន់ដែលប្រជាពលរដ្ឋតែងគោរពបូជា (ទីតាំងពិតប្រាកដអំពីព្រៃទាំងនេះ មិនបានកំណត់ច្បាស់លាស់ទេនៅពេលនេះ)។ ដីសហគមន៍ភូមិប្រឡេនៅចំណុចតំបន់ភ្នំទ្រូ និងភ្នំដូងមានប្រមាណ484 ហ.ត.។
    - បារម្ភអំពីការមិនលុបដីទៅលើដែលបានកាយរួច ទោះបីជាមានមួយចំនួនបានលុបវិញហើយក៏ដោយ។
    - បារម្ភអំពីការបោះបង្គោល និងបាញ់ថ្នាំក្រហមតាមដើមឈើ និងកន្លែងផ្សេងៗរបស់ក្រុមហ៊ុននៅក្នុងដីធ្លីស្រែ-ចំការរបស់ពួកគាត់ ដោយសារមិនដឹងថាមូលហេតុច្បាស់លាស់ (សិក្សាក្នុងជំរៅប៉ុន្មាន លើសពី 80ម. ឬយ៉ាងណា?)។
    - បារម្ភខ្លាចបាត់បង់ដីធ្លីដោយគ្មានការធ្វើសំណងពីក្រុមហ៊ុន និងខ្លាចការធ្វើសំណងរបស់ក្រុមហ៊ុន មិនបានមកដល់ដៃប្រជាពលរដ្ឋរងគ្រោះផ្ទាល់។
    - បារម្ភអំពីការបំពុលទឹក ដោយសារការប្រើប្រាស់សារធាតុគីមីគ្រោះថ្នាក់របស់ក្រុមហ៊ុន។
    - បារម្ភអំពីការបាត់បង់ព្រៃឈើ អាចបង្កឱ្យមានគ្រោះថ្នាក់ដូចជា ខ្យល់ព្យុះ និងការបាក់ដីជាដើម។
- សំណូមពរៈ
    - សុំឱ្យក្រុមហ៊ុនដាក់ពិន័យតឹងរឹងចំពោះបុគ្គលិក-កម្មកររបស់ខ្លួន ដោយមិនឱ្យធ្វើការកាប់បំផ្លាញផលដំណាំរបស់ប្រជាពលរដ្ឋដោយគ្មានការអនុញ្ញាត។
    - សុំឱ្យក្រុមហ៊ុនធ្វើទំនាក់ទំនងជាមួយប្រជាពលរដ្ឋ និងអាជ្ញាធរដែនដី មុននឹងធ្វើសកម្មភាពអ្វីមួយនៅក្នុងដីធ្លីកម្មសិទ្ធិទាំងនោះ។
    - សុំឱ្យក្រុមហ៊ុនជួយចូលរួមអភិវឌ្ឍន៍សហគមន៍មូលដ្ឋានដូចជា ជួយឧបត្ថម្ភជាថវិកា ឬសម្ភារៈផ្សេងៗដល់កុមារកំព្រា និងស្ត្រីមេម៉ាយនៅក្នុងភូមិនៅពេលដែលដំណើរការអជីវកម្មរបស់ខ្លួន។
    - សុំឱ្យក្រុមហ៊ុនជូនដំណឹង និងមកជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋាននៅពេលដែលទទួលបានការអនុញ្ញាតិពីរាជរដ្ឋាភិបាល (អាជ្ញាប័ណ្ណ) ឱ្យដំណើរការគំរោងរបស់ខ្លួន។

### ៥.២.២.៤. ការផ្សព្វផ្សាយ និងការជួបពិភាក្សាជាមួយអាជ្ញាធរ និងប្រជាពលរដ្ឋនៅក្នុងភូមិសោមគល់

ការផ្សព្វផ្សាយអំពីគំរោង និងការពិភាក្សាត្រូវបានធ្វើឡើងជាមួយលោកមេភូមិ អនុភូមិ សមាជិក និងប្រជាពលរដ្ឋមូលដ្ឋាន កាលពីថ្ងៃទី23 ខែវិច្ឆិកា ឆ្នាំ2010 នៅសាលាភូមិកក់ (រូបភាព29) ដើម្បីធ្វើការសាកសួរ ស្ទាបស្ទង់មតិ ជួបពិភាក្សា និងប្រមូលព័ត៌មានបន្ថែម ពីព្រោះភូមិនេះជាភូមិមួយមានប្រជាពលរដ្ឋរស់នៅ និងមានដីធ្លីស្រែ-ចំការនៅក្នុង

ទីតាំងតំរោង ( ការរៀបរាប់ដូចមានខាងលើ មិនត្រូវបានលើកមកនិយាយម្តងទៀតទេ) ។ ការពិគ្រោះយោបល់នេះបាន បង្ហាញឱ្យឃើញថា ប្រជាពលរដ្ឋមានចំណាប់អារម្មណ៍ ការបារម្ភ និងសំណូមពរដូចខាងក្រោមៈ

- ចំណាប់អារម្មណ៍ និងការបារម្ភៈ
  - បារម្ភអំពីដំណោះស្រាយរបស់ក្រុមហ៊ុនចំពោះដីធ្លីដែលប៉ះពាល់ និងការសងដីជូនម្ចាស់ដីវិញបន្ទាប់ពីជីក យករ៉ែរួច ។
  - បារម្ភអំពីអូរចង្វារ ដោយសារខ្លាចសកម្មភាពរបស់ក្រុមហ៊ុនធ្វើឱ្យលុបអូរនេះបាត់ (អូរនេះនៅមាន ត្រី) ។
  - បារម្ភអំពីការបោះបង្គោល និងបាញ់ថ្នាំក្រហមតាមដើមឈើ និងកន្លែងវៀងៗរបស់ក្រុមហ៊ុននៅក្នុងដី ធ្លីស្រែ-ចំការរបស់ពួកគាត់ ដោយសារដឹងថាមូលហេតុច្បាស់លាស់ ។
  - បារម្ភខ្លាចក្រុមហ៊ុនបន្លំមិនរាយការណ៍ការពិត (រាយការណ៍ថាអត់មានរ៉ែ ប៉ុន្តែលួចធ្វើស្ងាត់ៗ) ។
  - បារម្ភអំពីការមិនគោរពពាក្យសន្យារបស់ក្រុមហ៊ុន ព្រោះបទពិសោធន៍ធ្លាប់កើតមានរួចមកហើយ ដោយក្រុមហ៊ុនផ្សេងបានធ្វើការសន្យាថា បន្ទាប់ពីការសិក្សាស្រាវជ្រាវរួច ក្រុមហ៊ុននឹងរៀបចំលុប រណ្តៅ និងធ្វើផ្លូវឱ្យបានល្អ ប៉ុន្តែជាក់ស្តែងមិនបានធ្វើអ្វីទាំងអស់ ។
  - បារម្ភអំពីការប៉ះពាល់ដល់សតិអារម្មណ៍របស់ប្រជាពលរដ្ឋ ដោយសារសកម្មភាពចរាចរយានយន្តដឹក ជញ្ជូនរបស់ក្រុមហ៊ុន ដែលបានធ្វើឱ្យប៉ះពាល់ដល់ដំណាំរបស់ប្រជាពលរដ្ឋផ្សេងៗ (ចំការស្វាយចាន់ទី) ។
- សំណូមពរៈ
  - សុំឱ្យក្រុមហ៊ុនធ្វើការគោរពប្រពៃណី-ទំលៀមទំលាប់របស់សហគមន៍មូលដ្ឋាន ពីព្រោះជាប្រពៃណី-ទំលៀមទំលាប់ ប្រជាពលរដ្ឋតែងធ្វើការគោរព និងសែនព្រេននៅពេលដែលមានការរុះរើ ឬផ្លូវទីតាំង ដី-ផ្ទះផ្សេងៗ ។
  - សុំឱ្យក្រុមហ៊ុនធ្វើការដោះស្រាយបញ្ហាប៉ះពាល់ដីធ្លីប្រជាពលរដ្ឋឱ្យបានត្រឹមត្រូវ និងអាចទទួលយក បាន ។

### ៥.២.៣. ការស្ទង់មតិ និងពិគ្រោះយោបល់ជាមួយមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត

ការជួបសំភាសន៍ និងពិគ្រោះយោបល់ជាមួយ**លោក ហែម វណ្ណថន** (ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្ត រតនគិរី) កាលពីថ្ងៃទី18 ខែ វិច្ឆិកា ឆ្នាំ2010 នៅមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត (រូបភាព30) ត្រូវបានធ្វើឡើង ដើម្បីសាកសួរ និងប្រមូលព័ត៌មានបន្ថែមអំពីស្ថានភាពទូទៅនៅក្នុងតំបន់តំរោង (ការរៀបរាប់ដូចមានខាងលើ មិន ត្រូវបានលើកមកនិយាយម្តងទៀតទេ) ។

Draft

❖ ស្ថានភាពតំបន់ និងស្ថានភាពធម្មជាតិ-សង្គមៈ តំបន់គំរោង គឺជាតំបន់ខ្ពង់រាប និងសំបូរដោយកូនភ្នំ ហើយមានដីប្រភេទដីក្រហមដែលមានជីជាតិសំរាប់វិស័យកសិកម្ម។ ដោយសារប្រព័ន្ធផ្លូវទឹកមានតិចតួចនៅក្នុងតំបន់គំរោង ក្រុមហ៊ុនគួរស្វែងរកប្រភពទឹកបន្ថែម ដោយសារគំរោងអាជីវកម្មរ៉ែនឹងត្រូវការទឹកប្រើប្រាស់ច្រើន ហើយទឹកដែលមានប្រភពមកពីអូរកប អាចមិនមានគ្រប់គ្រាន់តាមតំរូវការ។ ដូច្នេះក្រុមហ៊ុនគួរប្រើប្រាស់ទឹកជាលក្ខណៈវិលវិញ (Recycle) ឬធ្វើអាងស្តុកទឹក។ នៅក្នុងទីតាំងគំរោង មិនមានការធ្វើអាជីវកម្មរ៉ែបែបអាណាធិបតេយ្យទេ លើកលែងតែតំបន់ផ្សេង។ កន្លងមកធ្លាប់មានការធ្វើសម្បទានដីសេដ្ឋកិច្ចសំរាប់ការអភិវឌ្ឍន៍ដំណាំកសិកម្ម និងកសិ-ឧស្សាហកម្មនៅក្នុងតំបន់តំបន់គំរោង។ ជាទូទៅគំរោងអភិវឌ្ឍន៍ដាំដំណាំកសិ-ឧស្សាហកម្មកៅស៊ូ មិនមានការប៉ះពាល់ធ្ងន់ធ្ងរដល់ទឹកទេ ប៉ុន្តែអាចមានការប៉ះពាល់ខ្លាំងប្រសិនបើសកម្មភាពទាំងនេះលើសពីការដាំដំណាំកៅស៊ូ (ឧ. លួចធ្វើអាជីវកម្មរ៉ែខុសច្បាប់)។ បច្ចុប្បន្នបញ្ហានេះមិនទាន់បានកើតឡើងនៅឡើយទេ ប្រសិនបើមាន មន្ទីរនឹងរៀបចំក្រុមការងារចុះធ្វើការសិក្សា។

សកម្មភាពកាប់ឈើឃើញថាមានការកើតឡើងច្រើន នៅក្នុងចន្លោះពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដែលក្នុងនោះប្រជាពលរដ្ឋមូលដ្ឋាន និងក្នុងតំបន់ ក៏បានធ្វើការកាប់ឈើសំរាប់សំណង់លំនៅដ្ឋាន ចំណែកឯប្រជាពលរដ្ឋខ្លះទៀតកាប់ឈើសំរាប់លក់យកថវិកា។ សត្វព្រៃបានបាត់បង់ជាច្រើន ហើយភាគច្រើនបានបំលាស់ទីទៅតំបន់លំផាត់ និងវីរៈជ័យ។ មកទល់បច្ចុប្បន្ន ការប៉ះពាល់សំខាន់ៗផ្សេងទៀត មិនទាន់ឃើញកើតមាននៅឡើយទេ ប៉ុន្តែមានប្រជាពលរដ្ឋមួយចំនួនបាននិយាយថា ក្រុមហ៊ុនបានយកដីធ្លីរបស់ពួកគាត់ ដែលទាំងនេះបង្កឡើងដោយភាគីផ្សេងទៀតមកបញ្ចុះបញ្ចូល។

❖ វត្តមានគំរោងៈ ការសិក្សាស្រាវជ្រាវរុករករ៉ែតែងបង្កឱ្យមានការប៉ះពាល់ ហើយកន្លែងខ្លះបានប៉ះពាល់ដល់ដីធ្លីស្រែចំការរបស់ប្រជាពលរដ្ឋ។ តាមច្បាប់ស្តីពីការគ្រប់គ្រងធនធាន និងការធ្វើអាជីវកម្មរ៉ែ (2001) ប្រសិនបើមានការប៉ះពាល់ ក្រុមហ៊ុនត្រូវធ្វើការចរចារ និងពិភាក្សាជាមួយជនរងគ្រោះ ហើយត្រូវស្វែងរកដំណោះស្រាយឱ្យបានសមស្របដែលអាចទទួលយកបានសំរាប់ភាគីពាក់ព័ន្ធទាំងអស់។ ការពង្រីកសកម្មភាពពីការសិក្សាស្រាវជ្រាវរុករកមកជាការធ្វើអាជីវកម្មរ៉ែ ពិតជាបានជួយដល់កំនើនសេដ្ឋកិច្ចតំបន់ និងជាតិ និងប្រជាពលរដ្ឋក្នុងតំបន់ និងមូលដ្ឋាន ដូច្នេះហើយលោកមិនមានមតិជំទាស់នឹងវត្តមានគំរោងអភិវឌ្ឍន៍របស់ក្រុមហ៊ុនទេ ប៉ុន្តែមន្ទីមនឹងនេះលោកក៏មានមតិ ការបារម្ភ និងសំណូមពរមួយចំនួនដែរដូចជាៈ

- បារម្ភៈ
  - បារម្ភខ្លាចសកម្មភាពធ្វើអាជីវកម្មរ៉ែដែករបស់ក្រុមហ៊ុនបង្កឱ្យកើតមានប៉ះពាល់ក្នុងកំរិតខ្ពស់ពេកហួសពីការស្មានទុក (ឧទាហរណ៍ ការប៉ះពាល់ដល់គុណភាពទឹក និងបរិស្ថានផ្សេងៗ)។ ទោះបីជាយ៉ាងណាការបារម្ភនេះនឹងថយចុះដោយសារក្រុមហ៊ុនតែងមានវិធានការ និងគោលការណ៍ក្នុងការគ្រប់គ្រងការ

Draft

ប៉ះពាល់ទាំងនេះបានច្បាស់លាស់ និងធ្វើយ៉ាងណាកុំឱ្យសកម្មភាពរបស់ខ្លួនបង្កឱ្យមានការប៉ះពាល់ដល់មជ្ឈដ្ឋានជុំវិញ និងប្រជាពលរដ្ឋ ។

   - បារម្ភអំពីការកាប់ឈើ និងការបំពុលទឹក ដែលបង្កឡើងដោយបុគ្គលិក-កម្មករក្រុមហ៊ុន និងសកម្មភាពរោងចក្រជាដើម ។

- សំណូមពរ:
   - ក្រុមហ៊ុនត្រូវសិក្សាឱ្យបានច្បាស់លាស់អំពីខ្សែសង្វាក់អាជីវកម្មរបស់ខ្លួន និងធានាឱ្យបានថាសកម្មភាពគំរោង ( ការសាងសង់ ការដឹកជញ្ជូន) នឹងមិនបង្កឱ្យមានការប៉ះពាល់ដល់បរិស្ថាន និងសង្គម ។

### ៥.៧.៤. ការស្ទង់មតិ និងការពិគ្រោះយោបល់ជាមួយមន្ទីរបរិស្ថានខេត្ត

ការជួបសំភាសន៍ និងពិគ្រោះយោបល់ជាមួយ**លោក ជា សុភក្រ្ត** ( ប្រធានមន្ទីរបរិស្ថានខេត្តរតនគិរី) កាលពីថ្ងៃទី25 ខែវិច្ឆិកា ឆ្នាំ2010 នៅមន្ទីរបរិស្ថានខេត្ត (រូបភាព៣០) ត្រូវបានធ្វើឡើង ដើម្បីសាកសួរ និងប្រមូលព័ត៌មានបន្ថែមអំពីស្ថានភាពទូទៅនៅក្នុងតំបន់គំរោង ( ការរៀបរាប់ដូចមានខាងលើ មិនត្រូវបានលើកមកនិយាយម្តងទៀតទេ) ។

- ស្ថានភាពតំបន់ និងស្ថានភាពធម្មជាតិ-សង្គម: ពាក់ព័ន្ធទៅនឹងស្ថានភាពព្រៃឈើជាក់ស្តែងនៅក្នុងតំបន់ លោកមិនបានដឹងច្បាស់លាស់នៅឡើយទេ ដោយសារលោកមិនទាន់បានចុះទៅពិនិត្យដល់ទីតាំងផ្ទាល់ ដោយសារមន្ទីរមិនទាន់បានទទួលលិខិតផ្លូវច្បាប់អំពីក្រុមហ៊ុន ដើម្បីចុះទៅពិនិត្យស្ថានភាពទូទៅនៅក្នុងទីតាំងគំរោង ។ ទោះបីជាយ៉ាងនេះក៏ដោយ ក៏លោកបានចាត់ក្រុមការងារឱ្យចុះធ្វើការសិក្សារួចហើយ ដើម្បីរាយការណ៍ជូនមន្ទីរ ។ ជាធម្មតាសកម្មភាពអភិវឌ្ឍន៍របស់គំរោងតែងបង្កឱ្យមានការប៉ះពាល់ ប៉ុន្តែប៉ះពាល់ក្នុងកំរិតណាមួយនោះនៅមិនទាន់អាចធ្វើការកំណត់ និងសន្និដ្ឋានបានទេ (ធ្លាប់បានឃើញថាមានការលប់រណ្តៅវិញបន្ទាប់ពីបានសិក្សាស្រាវជ្រាវរួចនៅប៉ុន្តែរណ្តៅខ្លះទៀតនៅមិនទាន់បានលុបនៅឡើយទេ) ។
- វត្តមានគំរោង: កន្លងមកធ្លាប់កើតមានបញ្ហាប៉ះពាល់ដីធ្លីស្រែ-ចំការរបស់ប្រជាពលរដ្ឋ (មានការដាក់ពាក្យបណ្តឹងទៀតផង) ដោយហេតុនេះហើយ លោកបានចាត់ក្រុមការងារចុះសិក្សាអំពីបញ្ហានេះ ដើម្បីបញ្ជាក់បន្ថែមអំពីមូលហេតុដែលនាំឱ្យកើតមានបញ្ហាទាំងនេះ ។ ជាមួយគ្នានេះដែរ លោកបានលើកឡើងនូវក្តីបារម្ភ និងសំណូមពរមួយចំនួនដូចតទៅ:
   - បារម្ភ:
      - បារម្ភខ្លាចក្រុមហ៊ុនដំណើរការអជីវកម្មរ៉ែរបស់ខ្លួន មុនពេលទទួលបានការអនុញ្ញាតិពីរាជរដ្ឋាភិបាល (ករណីនេះកើតមានចំពោះក្រុមហ៊ុនផ្សេងទៀតជាច្រើន) ។

- ○ បារម្ភអំពីការស្តារបរិស្ថានឡើងវិញនៅពេលបញ្ចប់អាជីវកម្ម (ព្រោះជាធម្មតានៅពេលបញ្ចប់គំរោង ក្រុមហ៊ុនតែងតែមិនបានស្តារបរិស្ថានឡើងវិញទេ) ។
- ○ បារម្ភអំពីការបំពុលទឹក ប្រសិនបើក្រុមហ៊ុនគ្រប់គ្រងមិនបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស និងទៅតាមការកំណត់របស់ស្ថាប័ន ឬសមត្ថកិច្ចជំនាញ (ឧ. ក្រសួងបរិស្ថាន ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលជាដើម) ។ មិនមានការបារម្ភធ្ងន់ធ្ងរ ចំពោះបញ្ហាបំពុលខ្យល់ទេ ដោយសារគំរោងមិនទាន់មានសកម្មភាពច្រើននៅឡើយទេ ម្យ៉ាងទៀតគំរោងមិនមែនជាប្រភេទគំរោងចំរាញ់រ៉ែលោហៈ ។

- សំណូមពរៈ
  - ○ សូមឱ្យក្រុមហ៊ុនសហការជាមួយមន្ទីរបរិស្ថានឱ្យបានល្អ ជាពិសេសនៅពេលដែលមានបេសកកម្មចុះពិនិត្យ និងអង្កេតតាមដានសកម្មភាពផ្សេងៗរបស់គំរោង ក៏ដូចជាការចុះពិនិត្យបញ្ហាបរិស្ថាននៅក្នុងទីតាំង និងតំបន់គំរោង ។
  - ○ សូមឱ្យក្រុមហ៊ុនដំណើរការអាជីវកម្មរបស់ខ្លួនឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ដែលមិនបង្កឱ្យមានការប៉ះពាល់ ឬបំពុលទឹក និងដីជាដើម ។
  - ○ សូមឱ្យក្រុមហ៊ុនធ្វើការចាក់បំពេញទីតាំងដែលកាយយករ៉ែ ដើម្បីធ្វើការដាំដុះ និងត្រូវធ្វើការឃ្លាំមើលឱ្យបានច្បាស់លាស់ចៀសវាងមានជនណាចូលមកក្នុងទីតាំង និងអះអាងថាជាដីរបស់ពួកគាត់ ។
  - ○ សូមឱ្យក្រុមហ៊ុនដំណើរការអាជីវកម្មរបស់ខ្លួន បន្ទាប់ពីទទួលបានការអនុញ្ញាតិពីរាជរដ្ឋាភិបាល (ទទួលបានគ្រប់ឯកសារផ្លូវច្បាប់) ដើម្បីចៀសវាងការប៉ះពាល់ផ្សេងៗដូចជា បរិស្ថាន និងសង្គម ។

### ៥.២.៥. ការស្ទង់មតិ និងការពិគ្រោះយោបល់ជាមួយមន្ទីរកសិកម្មខេត្ត

ការជួបសំភាសន៍ និងពិគ្រោះយោបល់ជាមួយ**លោក សយ សូណា** (ប្រធានមន្ទីរកសិកម្មខេត្តរតនគីរី) កាលពីថ្ងៃទី19 ខែវិច្ឆិកា ឆ្នាំ2010 នៅមន្ទីរកសិកម្មខេត្ត (រូបភាព30) ត្រូវបានធ្វើឡើង ដើម្បីសាកសួរ និងប្រមូលព័ត៌មានបន្ថែមអំពីស្ថានភាពទូទៅនៅក្នុងតំបន់គំរោង (ការរៀបរាប់ដូចមានខាងលើ មិនត្រូវបានលើកមកនិយាយម្តងទៀតទេ) ។

- ❖ ស្ថានភាពតំបន់ និងស្ថានភាពធម្មជាតិ-សង្គមៈ តំបន់គំរោង គឺជាតំបន់ដែលដីមានជីជាតិសំរាប់ការធ្វើកសិកម្ម ហើយមានប្រជាពលរដ្ឋរស់នៅជុំវិញច្រើនជាជនជាតិដើមភាគតិចចារាយ ដែលពួកគាត់ប្រកបមុខរបរចិញ្ចឹមជីវិតដោយធ្វើស្រែ-ចំការ និងដាំដំណាំ។ ចាប់ផ្តើមដាំតាំពីឆ្នាំ2001 ពួកគាត់បានធ្វើការដាំដំណាំស្វាយចន្ទី បន្ថែមទៅលើដំណាំផ្សេងទៀត ដែលពួកគាត់បានដាំ។ នៅក្នុងតំបន់គំរោងមានភ្លៀងធ្លាក់ជាធម្មតា (មិនមានគ្រោះថ្នាក់ធម្មជាតិទេ) ។ ប្រព័ន្ធផ្លូវទឹកនៅក្នុងតំបន់មានអូរមួយចំនួន ហើយទោះបីជាមិនមានព័ត៌មានអំពីបរិមាណទឹក

ច្បាស់លាស់ក៏ដោយ ក៏ភាគច្រើននៃទឹកនៅតាមដងអូរទាំងនេះទទួលរងនូវការរីងស្ងួត ឬនៅមានតិចតួចនៅរដូវប្រាំង។ ដូច្នេះការប្រើប្រាស់ទឹកមិនត្រូវខ្ជះខ្ជាយ ចៀសវាងការប្រើប្រាស់ទឹកអត់ប្រយោជន៍។

ស្ថានភាពព្រៃឈើនៅក្នុងតំបន់នេះមានការប្រែប្រួល និងបាត់បង់ពីមួយឆ្នាំទៅមួយឆ្នាំ ដែលទាំងនេះបណ្តាលមកពីកត្តាជាច្រើនដូចជា មានការកាប់ព្រៃដើម្បីសង់លំនៅដ្ឋាន និងធ្វើស្រែ-ចំការជាលក្ខណៈអចិន្ត្រៃយ៍ និងលក្ខណៈពនេចរ (បោះបង់ចោលក្រោយពេល03–04ឆ្នាំ ទៅកាប់ព្រៃកន្លែងផ្សេងទៀត) របស់ប្រជាពលរដ្ឋ និងការលួចកាប់ឈើខុសច្បាប់របស់ជនខិលខូចមួយចំនួន។ បន្ថែមពីលើនេះទៀតដែរ ប្រជាពលរដ្ឋដែលមានដីរានរួចបានលក់ទៅឱ្យឈ្មួញ ហើយក៏មានអ្នកវិនិយោគឯកជនផ្សេងទៀតដែរបានមកធ្វើការទិញដី និងធ្វើការដាំដុះដំណាំអចិន្ត្រៃយ៍ដូចជា កៅស៊ូ និងស្វាយចាន់ទីជាដើម។ មកទល់បច្ចុប្បន្ន ស្ថានភាពព្រៃឈើស្ថិតក្នុងស្ថានភាពកំណត់មិនច្បាស់លាស់ ហើយការកំណត់ចុះបញ្ជីដីសហគមន៍ក៏មិនទាន់មាន ដែលទាំងនេះជាកត្តាមួយនាំសហគមន៍មូលដ្ឋាន និងមជ្ឈដ្ឋានខាងក្រៅអាចធ្វើការកាប់រានដីព្រៃ សំរាប់ធ្វើស្រែ-ចំការជាដើម។ សត្វព្រៃនៅក្នុងតំបន់ ក៏មានការបាត់បង់ និងថយចុះ ដោយសារការបរបាញ់ និងចាប់សត្វរបស់សកម្មភាពមនុស្ស និងបំលាស់ទីទៅតំបន់ផ្សេងៗដែលមានទីជំរក និងសុវត្ថិភាព។

❖ វត្តមានគំរោង: លោកធ្លាប់បានដឹងលឺអំពីគំរោងអភិវឌ្ឍន៍របស់ក្រុមហ៊ុន ហើយលោកមិនមានមតិជំទាស់នឹងគំរោងអភិវឌ្ឍន៍នេះដែរ ព្រោះវាជាការសំរេចចិត្តរបស់រាជរដ្ឋាភិបាល។ ប្រសិនបើទុកដីនេះចោលទំនេរ វានឹងបាត់បង់ផលប្រយោជន៍ជាតិជាងការធ្វើវិនិយោគរបស់ក្រុមហ៊ុន។ ទោះបីជាយ៉ាងនេះក្តី លោកបានលើកឡើងនូវក្តីបារម្ភ និងសំណូមពរមួយចំនួនដូចខាងក្រោម:

- បារម្ភ:
    - បារម្ភអំពីដំណើរការអាជីវកម្មរបស់ក្រុមហ៊ុននឹងធ្វើឱ្យប៉ះពាល់ដល់ដីធ្លីស្រែ-ចំការ (ស្វាយចាន់ទី) ដែលប្រជាពលរដ្ឋបានចាប់ផ្តើមដាំតាំងពីឆ្នាំ2000–2001 មកម្ល៉េះ។
    - បារម្ភអំពីការប៉ះពាល់ទៅលើដើមឈើ រុក្ខជាតិ និងជីវៈចំរុះផ្សេងទៀត ដោយសារសកម្មភាពយករ៉ែ។
    - បារម្ភអំពីការប៉ះពាល់ដល់ដីអ្នកតា ដែលជនជាតិដើមភាគតិចតែងតែគោរព (ដីអារក្ស-អ្នកតា) និងការប៉ះពាល់ដល់គុណភាពដី ដែលក្លាយទៅជាគ្មានជីជាតិបន្ទាប់ពីដីស្រទាប់លើត្រូវបានកាយចេញ ហើយដីដែលលុបមកវិញមិនអាចធ្វើការដាំដុះបាន។
    - ក្រុមហ៊ុនត្រូវគ្រប់គ្រងការបំពុលទឹកឱ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស ចៀសវាងការបំពុលទឹកដល់ផ្នែកខាងក្រោមខ្សែទឹក។
- សំណូមពរ:

- ក្រុមហ៊ុនត្រូវសិក្សាឱ្យបានច្បាស់លាស់ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ និងជំនាញ (ក្រសួងកសិកម្ម ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងបរិស្ថាន) ដើម្បីសិក្សា និងដោះស្រាយបញ្ហាសង្គម (ការប៉ះពាល់ដីធ្លីស្រែ-ចំការរបស់ប្រជាពលរដ្ឋ) ឱ្យបានស្របទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលមុននឹងដំណើរការអាជីវកម្ម។
- នៅពេលទទួលបានការអនុញ្ញាតិពីរាជរដ្ឋាភិបាលឱ្យដំណើរការអាជីវកម្មរ៉ែ ក្រុមហ៊ុនគួរកំណត់ព្រំដីឱ្យបានច្បាស់លាស់ និងធ្វើការសំរបសំរួលជាមួយអាជ្ញាធរដែនដី និងប្រជាពលរដ្ឋឱ្យបានល្អ។

### ៥.២.៦. ការស្ទង់មតិ និងពិគ្រោះយោបល់ជាមួយខ័ណ្ឌរដ្ឋបាលព្រៃឈើខេត្ត

ការជួបសំភាសន៍ និងពិគ្រោះយោបល់ជាមួយ**លោក យូ កាណារិមាន** (នាយខ័ណ្ឌរដ្ឋបាលព្រៃឈើខេត្តរតនគិរី) កាលពីថ្ងៃទី18 ខែវិច្ឆិកា ឆ្នាំ2010 នៅទីស្នាក់ការខ័ណ្ឌរដ្ឋបាលព្រៃឈើខេត្ត (រូបភាព30) ត្រូវបានធ្វើឡើង ដើម្បីធ្វើការសាកសួរ ស្ទាបស្ទង់មតិ ជួបពិភាក្សា និងប្រមូលព័ត៌មានបន្ថែម (ការរៀបរាប់ដូចមានខាងលើ មិនត្រូវបានលើកមកនិយាយម្តងទៀត ទេ)។

- ស្ថានភាពតំបន់: ប្រមាណ05ឆ្នាំចុងក្រោយមកទល់បច្ចុប្បន្ន ស្ថានភាពព្រៃឈើនៅក្នុងតំបន់គំរោងមានការប្រែប្រួល និងថយចុះច្រើន ដោយសារការកាប់រានព្រៃរបស់ប្រជាពលរដ្ឋ ដើម្បីធ្វើស្រែ-ចំការ (ទាំងលក្ខណៈអចិន្ត្រៃយ៍ និងពនេចរ) និងការលួចកាប់ឈើរបស់ជនខិលខូច។ ប្រភេទឈើមានតំលៃពាណិជ្ជកម្ម ត្រូវបានបាត់បង់អស់ជាច្រើនហើយ ចំណែកឯប្រភេទឈើមានតំលៃដូចជា បេង នាងនួន ក្រញូង អាចនៅមានខ្លះ។ ទន្ទឹមគ្នានេះដែរ សត្វព្រៃធំៗដូចជាប្រភេទដំរី ខ្លា លែងមានទៀតហើយដែរ។ ភាគច្រើននៃសត្វដែលនៅមានវត្តមានច្រើនរួមមាន សត្វពស់ ទន្សាយ ត្រកួត ជ្រូកព្រៃជាដើម។
- វត្តមានគំរោង: លោកធ្លាប់បានដឹងច្បាស់អំពីគំរោងអាជីវកម្មរ៉ែរបស់ក្រុមហ៊ុន ព្រោះវាស្ថិតនៅក្នុងស្រុកអូរយ៉ាដាវ ដែលជាដែនសមត្ថកិច្ចមួយនៅក្រោយការគ្រប់គ្រងរបស់រដ្ឋបាលព្រៃឈើខេត្ត និងដោយសារការកើតឡើងនូវបញ្ហាប៉ះពាល់ដីធ្លីស្រែ-ចំការរបស់ប្រជាពលរដមូលដ្ឋាន។ បញ្ហាត្រួតស៊ីគ្នារវាងដីអាជីវកម្មរ៉ែរបស់ក្រុមហ៊ុន និងប្រជាពលរដ្ឋ ក្រុមហ៊ុនបាននឹងកំពុងដោះស្រាយ ហើយក៏មិនទាន់មានបញ្ហាធ្ងន់ធ្ងរកើតឡើងបន្ថែមទៀតដែរ។ ទោះបីជាយ៉ាងនេះក៏ដោយ ក៏លោកមិនមានមតិជំទាស់នឹងវត្តមានគំរោងអភិវឌ្ឍន៍នេះដែរ ព្រោះវាជាការសំរេចចិត្តរបស់រាជរដ្ឋាភិបាល។ ទន្ទឹមនឹងនេះដែរ លោកបានលើកឡើងនូវក្តីបារម្ភ និងសំណូមពរមួយចំនួនដូចតទៅ:
  - បារម្ភអំពីការប៉ះពាល់ដល់ព្រៃឈើនៅក្នុង និងនៅក្រៅទីតាំងគំរោងដោយសារសកម្មភាពគំរោងដូចជា ការធ្វើផ្លូវថ្មីសំរាប់ការដឹកជញ្ជូនជាដើម ដែលទាំងនេះអាចធ្វើឱ្យថយចុះនូវទិន្នន័យគំរបព្រៃប្រទេស។

Draft

- ក្រុមហ៊ុនត្រូវមានលិខិតអនុញ្ញាតិពីរាជរដ្ឋាភិបាលនៅពេលដែលមានការកាប់ និងដឹកជញ្ជូនឈើចេញពីទីតាំងគំរោង ហើយត្រូវរៀបចំធ្វើការបង់ពន្ធជូនរដ្ឋឱ្យបានត្រឹមត្រូវ ។
- ក្រុមហ៊ុនត្រូវធ្វើការសហការជាមួយសហគមន៍មូលដ្ឋាន និងអជ្ញាធរដែនដីឱ្យបានល្អ ដើម្បីជៀសវាងនូវបញ្ហាផ្សេងៗកើតមានក្នុងអំឡុងពេលធ្វើអាជីវកម្ម ។
- ក្រុមហ៊ុនត្រូវបង្ហាញ និងត្រូវគោរពតាមកិច្ចសន្យានានារបស់ខ្លួនដូចជា គោរពតាមផែនការមេដែលបញ្ជាក់ច្បាស់លាស់អំពីផែនការនៃការគ្រប់គ្រងសំណល់គ្រប់ប្រភេទជូនស្ថាប័ន និងអាជ្ញាធរជំនាញ ដើម្បីឱ្យអាចទទួលយកទាំងអស់គ្នាបាន ។
- ក្រុមហ៊ុនត្រូវផ្តល់អទិភាពការងារដល់ប្រជាពលរដ្ឋមូលដ្ឋាន និងក្នុងតំបន់ ។

### ៥.២.៧. ការស្ទង់មតិ និងការពិគ្រោះយោបល់ជាមួយសង្កាត់រដ្ឋបាលជលផលខេត្ត

ការជួបសំភាសន៍ និងពិគ្រោះយោបល់ជាមួយ**លោក ខៀង ឡេច** (នាយសង្កាត់រដ្ឋបាលជលផលស្រុកអូរយ៉ាដាវ) កាលពីថ្ងៃទី22 ខែ វិច្ឆិកា ឆ្នាំ2010 នៅមន្ទីរកសិកម្មខេត្ត (រូបភាព30) ត្រូវបានធ្វើឡើង ដើម្បីសាកសួរ និងប្រមូលព័ត៌មានបន្ថែមអំពីស្ថានភាពទូទៅនៅក្នុងតំបន់គំរោង (ការរៀបរាប់ដូចមានខាងលើ មិនត្រូវបានលើកមកនិយាយម្តងទៀតទេ) ។

- ស្ថានភាពតំបន់ និងស្ថានភាពធម្មជាតិ-សង្គមៈ នៅក្នុងតំបន់គំរោងមិនមានប្រព័ន្ធផ្លូវទឹកធំៗទេ លើកលែងតែអូរតូចៗ និងប្រឡាយ ។ អូរកប ជាអូរមួយដែលមានទឹកជាប្រចាំ (តិច ឬច្រើនទៅតាមរដូវ និងទៅភ្លៀងធ្លាក់) ហើយនៅក្នុងអូរនេះធ្លាប់មានត្រីប្រភេទមេពូជដូចជា ត្រីក្រាបី ត្រីឆ្លាំង ត្រីស្លាក់ ត្រីរមាស ត្រីត្រចៀកដំរី ត្រីឆ្ពិនត្រីស្មោរ ត្រីរស់ ត្រីផ្ទក់ ត្រីអំបូង ត្រីប្រាជាដើម ។ ដោយសារមានសកម្មភាពខុសច្បាប់ដូចជា ការនេសាទ និងការចាប់ត្រី និងការកាប់បំផ្លាញព្រៃឈើ ក៏ដូចជាការហូរច្រោះដីទៅក្នុងអូរ (ធ្វើឱ្យជំរៅទឹកអូរ និងអន្លង់ត្រីក្លាយទៅជារាក់) ធនធានត្រីដែលធ្លាប់មានពីមុនបាត់បង់អស់ទៅវិញជាច្រើន ហើយស្ថានភាពធនធានត្រីដែលបាត់បង់អាចមាន ដល់ទៅប្រមាណ80%នៃធនធានត្រីដែលធ្លាប់មាន ។ ជាមួយគ្នានេះដែរ ខ័ណ្ឌរដ្ឋបាលជលផលគ្រោងនឹងសហការជាមួយអាជ្ញាធរដែនដី និងប្រជានេសាទ ដើម្បីរៀបចំចុះបញ្ជីបង្កើតសហគមន៍នេសាទតងតួមបខាំ និងកែងសាងតាឡាវ ។ ទោះបីជាយ៉ាងណា គំរោងនេះស្ថិតនៅឆ្ងាយពីតំបន់គំរោង គឺស្ថិតនៅក្នុងស្រុកអណ្តូងមាស ។
- វត្តមានគំរោងៈ លោកធ្លាប់បានដឹងលឺអំពីគំរោងអភិវឌ្ឍន៍ធ្វើអាជីវកម្មរ៉ែរបស់ក្រុមហ៊ុន ប៉ុន្តែលោកមិនដែលបានចុះទៅពិនិត្យដល់ទីតាំងជាក់ស្តែងនៅឡើយទេ ។ ជាមួយគ្នានេះដែរ លោកក៏ធ្លាប់បានដឹងលឺអំពីបញ្ហាប៉ះពាល់ដីធ្លីស្រែ-ចំការរបស់ប្រជាពលរដ្ឋ ហើយក៏ធ្លាប់បានដឹងលឺថា គំរោងបានធ្វើឱ្យប៉ះពាល់ដល់ប្រព័ន្ធទឹកប្រឡាយ (ធ្វើឱ្យ

ទឹកល្អក់) និងព្រៃឈើ ។ បន្ទាប់ពីមានការដោះស្រាយ ស្ថានភាពទាំងនេះបានស្ងប់ស្ងាត់ទៅវិញបន្តិច ។ ជាមួយគ្នានេះដែរ លោកបានលើកឡើងនូវក្តីបារម្ភ និងសំណូមពរមួយចំនួនដូចតទៅ:

- បារម្ភ:
  - បារម្ភទៅលើការបាត់បង់ធនធានផលផល ព្រោះនៅមានត្រីមួយចំនួនទៀត មិនទាន់បានស្គាល់ឈ្មោះនៅឡើយ ។
- សំណូមពរ:
  - សូមឱ្យក្រុមហ៊ុននេះទទួលស្គាល់ពីរាជរដ្ឋាភិបាលអនុញ្ញាតិឱ្យធ្វើអាជីវកម្មរ៉ែនៅក្នុងទីតាំងនេះ (ព្រោះបើគំរោងនេះ ជាគំរោងធ្វើអាជីវកម្មពិតមែនអាចជួយដល់សេដ្ឋកិច្ចតំបន់) និងត្រូវចុះធ្វើការសិក្សាផលប៉ះពាល់ (ដីស្រែ-ចំការ ផ្ទះសំបែង) ជាមួយប្រជាពលរដ្ឋមូលដ្ឋាន និងដោះស្រាយបញ្ហាកើតឡើងជាមួយពួកគាត់ឱ្យបានត្រឹមត្រូវ ។
  - សូមឱ្យក្រុមហ៊ុនធ្វើការគ្រប់គ្រងសំណល់គ្រប់ប្រភេទ (រឹង-រាវ) ឱ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស និងមិនបង្កសកម្មភាពណាដែលបំពុលដល់បរិស្ថាន ។
  - សូមឱ្យក្រុមហ៊ុនជួយអភិវឌ្ឍន៍សហគមន៍មូលដ្ឋាន ដោយមានជាកញ្ចប់ថវិកាសំរាប់ជួយដល់សហគមន៍មូលដ្ឋានដូចជា បណ្តុះបណ្តាលវិជ្ជាជីវៈ និងបច្ចេកទេសចិញ្ចឹមសត្វ និងដាំដំណាំជាដើម ។
  - សូមឱ្យក្រុមហ៊ុនជួយជ្រើសរើសប្រជាពលរដ្ឋឱ្យបានចូលបំរើការងារនៅក្នុងគំរោង ។

### ៥.២.៤. ការស្ទង់មតិ និងពិគ្រោះយោបល់ជាមួយមន្ទីរធនធានទឹក និងឧតុនិយមខេត្ត

ការជួបសំភាសន៍ និងពិគ្រោះយោបល់ជាមួយមន្ត្រីជំនាញនៃមន្ទីរធនធានទឹក និងឧតុនិយមខេត្ត កាលពីថ្ងៃទី19 ខែវិច្ឆិកា ឆ្នាំ2010 នៅមន្ទីរធនធានទឹក និងឧតុនិយមខេត្ត (រូបភាព30) ត្រូវបានធ្វើឡើង ដើម្បីសាកសួរ និងប្រមូលព័ត៌មានបន្ថែមអំពីស្ថានភាពទូទៅនៅក្នុងតំបន់គំរោង (ការរៀបរាប់ដូចមានខាងលើ មិនត្រូវបានលើកមកនិយាយម្តងទៀតទេ) ។ ការពិគ្រោះយោបល់បានបង្ហាញឱ្យឃើញថា អាកាសធាតុនៅរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះមិនមានការប្រែប្រួលខ្លាំងនោះទេ ហើយប្រព័ន្ធផ្លូវទឹកនៅក្នុងតំបន់គំរោងក៏មិនសូវមានច្រើនដែរ ។ មកទល់បច្ចុប្បន្ន ការសិក្សាអំពីប្រព័ន្ធផ្លូវទឹក ធនធានទឹក និងបរិមាណទឹកនៅក្នុងតំបន់ (ឧ. បរិមាណទឹកនៅក្នុងអូរកប) ដោយមន្ទីរធនធានទឹក និងឧតុនិយម ឬស្ថាប័នផ្សេងទៀតក៏មិនទាន់មានទេ ។ នៅក្នុងតំបន់គំរោង អូរកប គឺជាអូរមួយដែលហូរកាត់ទីតាំងគំរោង មុននឹងហូរចាក់ចូលទៅក្នុងទន្លេសេសាន ។ ជាទូទៅអូរកបនេះមានទឹកជាប្រចាំ ហើយទឹកទាំងនេះត្រូវបានប្រើប្រាស់ដោយប្រជាពលរដ្ឋ សត្វ និងរុក្ខជាតិគ្រប់ប្រភេទតាមបណ្តោយអូរនេះ ។ ដូច្នេះប្រសិនបើសកម្មភាពណាមួយ

Draft

ធ្វើឱ្យបំពុលគុណភាព និងថយចុះបរិមាណទឹកនេះ នោះការប៉ះពាល់ទៅលើមនុស្ស សត្វ និងរុក្ខជាតិ នឹងមានវិសាល-ភាពធំ និងធ្ងន់ធ្ងរ ។

លោកធ្លាប់បានដឹងលឺរំពីគំរោងអភិវឌ្ឍន៍សិក្សាស្រាវជ្រាវ និងធ្វើអាជីវកម្មរ៉ែ និងគំរោងអភិវឌ្ឍន៍ដាំដំណាំកសិកម្ម និងកសិ-ឧស្សាហកម្ម (កៅស៊ូ) នៅក្នុងតំបន់ស្រុកបរកែវ និងស្រុកអូរយ៉ាដាវ ប៉ុន្តែលោកមិនបានដឹងច្បាស់អំពីទីតាំង និងសកម្មភាពអនុវត្តន៍របស់គំរោងធ្វើអាជីវកម្មរបស់ក្រុមហ៊ុនទេ ។ ដោយហេតុនេះហើយ លោកក៏មិនមានមតិអ្វីទៅលើគំរោងអភិវឌ្ឍន៍នេះដែរ ។ អ្វីដែលសំខាន់នោះ គឺរាជរដ្ឋាភិបាល និងស្ថាប័នជំនាញ ដែលមានសមត្ថកិច្ចក្នុងការសំរេចទាំងផ្នែកបច្ចេកទេស និងសេដ្ឋកិច្ច ។

### ៥.៣. មតិយោបល់ និងការបកស្រាយរបស់ក្រុមហ៊ុន

ជាការឆ្លើយតបទៅនឹងមតិយោបល់ ចំណាប់អារម្មណ៍ ការបារម្ភ និងសំណូមពរ ដែលបានលើកឡើងពីបណ្តាស្ថាប័ន-មន្ទីរជំនាញពាក់ព័ន្ធ អាជ្ញាធរដែនដី និងប្រជាពលរដ្ឋមូលដ្ឋាន ក្រុមហ៊ុនក៏មានមតិយោបល់ ការបកស្រាយ និងសំណូមពរដូចតទៅ:

- បទដ្ឋានបច្ចេកទេស និងគោលការណ៍ច្បាប់: ក្រុមហ៊ុននេះជាក្រុមហ៊ុនស្របច្បាប់ ។ កន្លងមកក្រុមហ៊ុនទទួលបានការអនុញ្ញាតិពីរាជរដ្ឋាភិបាលឱ្យធ្វើការសិក្សាស្រាវជ្រាវរុករករ៉ែ ហើយបច្ចុប្បន្នក្រុមហ៊ុនបាននឹងកំពុងស្នើសុំការអនុញ្ញាតិពីរាជរដ្ឋាភិបាល ដើម្បីធ្វើអាជីវកម្មរ៉ែដែក ដូច្នេះប្រសិនបើមានប៉ះពាល់ផ្សេងៗ ក្រុមហ៊ុននឹងធ្វើការដោះស្រាយឱ្យបានល្អបំផុត ។ ក្រុមហ៊ុននឹងដំណើរការអាជីវកម្មរបស់ខ្លួនឱ្យបានត្រឹមត្រូវ និងស្របទៅតាមបទដ្ឋានបច្ចេកទេស និងគោលការណ៍ច្បាប់នៅក្នុងប្រទេសកម្ពុជា ដោយមិនអនុវត្តន៍សកម្មភាពណាដែលអាចបង្កឱ្យមានគ្រោះថ្នាក់ ឬប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថាន និងសង្គម ។ ក្រុមហ៊ុននឹងមិនប្រើប្រាស់សារធាតុគីមីគ្រោះថ្នាក់នៅក្នុងខ្សែសង្វាក់អាជីវកម្មទេ ហើយទឹកដែលប្រើប្រាស់ក្នុងខ្សែសង្វាក់អាជីវកម្មនេះ គឺប្រើជាលក្ខណៈវិលជុំ (Recycle) មិនខ្ជះខ្ជាយ និងមានអាងចំរោះយកទឹកនិងមិនបញ្ចេញកាកសំណល់គ្រោះថ្នាក់ដែរ ។ ក្រុមហ៊ុននឹងធ្វើការដាក់លូ (ឬស្ពាន) ប្រសិនបើមានការប៉ះពាល់ដល់ប្រព័ន្ធផ្លូវឆ្លងកាត់អូរ ដើម្បីចៀសវាងកុំឱ្យបង្កការប៉ះ-ពាល់ដល់គុណភាពទឹក ។
- ជូនដំណឹង និងសហការ: នៅពេលក្រុមហ៊ុនបានទទួលការអនុញ្ញាតិពីរាជរដ្ឋាភិបាលឱ្យដំណើរការអាជីវកម្មរ៉ែដែក ក្រុមហ៊ុននឹងសហការយ៉ាងស្អិតរមួតជាមួយស្ថាប័នជំនាញ អាជ្ញាធរដែនដី និងប្រជាពលរដ្ឋមូលដ្ឋាន ដើម្បីឱ្យភាគីទាំងអស់បានដឹងអំពីសកម្មភាពរបស់ខ្លួន ។
- ទីសក្ការៈបូជារបស់ប្រជាពលរដ្ឋ: នៅពេលបោះព្រំដី ដើម្បីកំណត់ទីតាំងសំរាប់យករ៉ែដោយមានការយល់ព្រមពីរាជរដ្ឋាភិបាល ហើយនៅពេលនោះប្រសិនបើមានការប៉ះពាក់ដល់ទីសាការៈបូជារបស់ប្រជាពលរដ្ឋ ក្រុមហ៊ុននឹង

Draft

ធ្វើការពិភាក្សាអំពីបញ្ហានេះ ដោយសុំយោបល់ និងការសំរេចចិត្តពីរាជរដ្ឋាភិបាល។ ជាក់ស្តែងមកទល់បច្ចុប្បន្ន ក្រុមហ៊ុនពុំទាន់បានប្រទះ ឬប៉ះពាល់ទីតាំងដែលជាទីសក្ការៈរបស់ប្រជាពលរដ្ឋនៅឡើយទេ ។

- ដីសម្បទានសេដ្ឋកិច្ចដែលស្នើសុំ: ក្រុមហ៊ុនបានស្នើសុំសម្បទានដីសេដ្ឋកិច្ចសំរាប់ការធ្វើអាជីវកម្មរ៉ែដែកក្នុងទំហំ 4.000ហ.ត. ក៏ពិតមែន ប៉ុន្តែជាក់ស្តែងក្រុមហ៊ុនមិនបានធ្វើការជីកយករ៉ែទាំងអស់នៅក្នុងទំហំផ្ទៃដីនេះទេ គឺធ្វើតែនៅលើទីតាំងណាដែលមានសក្តានុពលរ៉ែប៉ុណ្ណោះ ។
- សំណង និងការលើកទឹកចិត្ត: ក្រុមហ៊ុននឹងសិក្សាអំពីផ្ទៃដីធ្លីដែលប៉ះពាល់របស់ប្រជាពលរដ្ឋ រួចហើយធ្វើការផ្សព្វផ្សាយ ឬជូនដំណឹងដល់ប្រជាពលរដ្ឋ និងអជ្ញាធរដែនដីដើម្បីធ្វើសំណង។ សំណងរួមមាន ១). ចំពោះស្រែ-ចំការអចិន្ត្រៃយ៍: ក្រុមហ៊ុននឹងបង់ថវិកាទូទាត់ជូនប្រជាពលរដ្ឋរងគ្រោះ ដោយផ្អែកទៅតាមប្រភេទដំណាំ និងទិន្នផលទទួលបានក្នុងមួយឆ្នាំ។ ២). ចំពោះស្រែ-ចំការពនេតចរ: ក្រុមហ៊ុននឹងបង់ថវិកាទៅលើកំលាំងពលកម្មដែលបានកាប់ឆ្ការរួច ៣). ការបង់ថវិកាជាសំណងនេះនឹងធ្វើឡើងជារៀងរាល់ឆ្នាំក្នុងកំឡុងពេលដំណើរការអាជីវកម្មរបស់ខ្លួន និង ៤). ថវិកាសំណងនេះនឹងបានទៅដល់ដៃរបស់ប្រជាពលរដ្ឋរងគ្រោះ ដោយមានអជ្ញាធរដែនដីដឹងលឺ និងទទួលស្គាល់។ ក្រុមហ៊ុននឹងផ្តល់ជាសំភារៈ (អង្ករ ខោអាវ) ដល់ប្រជាពលរដ្ឋទូទៅក្នុងតំបន់ (មិនមែនតែចំពោះប្រជា-ពលរដ្ឋប៉ះពាល់ផ្ទាល់) ប៉ុន្តែត្រូវឡើងតាមរយៈការស្នើសុំរបស់អាជ្ញាធរមូលដ្ឋាន និងរាជរដ្ឋាភិបាល ។
- ការសងដីជូនម្ចាស់ដី: ក្រុមហ៊ុនធ្វើអាជីវកម្មរ៉ែដោយធ្វើការកាយដីស្រទាប់ខាងលើចេញ និងជីកយកល្បាយអាចម៍រ៉ែនៅស្រទាប់ក្រោម បន្ទាប់ពីជីកយកល្បាយអាចម៍រ៉ែរួច ក្រុមហ៊ុនធ្វើការចាក់ដីលុបបំពេញវិញ ហើយដីនេះអាចធ្វើការដាំដុះដំណាំបានជាធម្មតា ។
- ឱកាសការងារ និងការចូលរួមអភិវឌ្ឍន៏សហគមន៏មូលដ្ឋាន: ក្រុមហ៊ុននឹងផ្តល់អាទិភាពដល់ប្រជាពលរដ្ឋមូលដ្ឋាន (ជាពិសេសប្រជាពលរដ្ឋដែលប៉ះពាល់) ឱ្យបានជ្រើសរើសចូលបំរើការងារនៅក្នុងក្រុមហ៊ុន និងបង្កើតឱ្យមានកម្មវិធីបណ្តុះបណ្តាលដល់ពួកគាត់ទាំងនោះឱ្យមានសម្ថភាពក្នុងការបំពេញភារកិច្ចរបស់ខ្លួន (អាចទទួលបានការបណ្តុះបណ្តាលនៅក្រៅប្រទេសទៀតផង) ។ ទោះបីជាមិនទាន់ឈានទៅដល់ការសំរេចចុងក្រោយនៅឡើយ ក្រុមហ៊ុននឹងពិនិត្យមើលលទ្ធភាពក្នុងការចូលរួមអភិវឌ្ឍន៏សហគមន៏មូលដ្ឋានដូចជា ជួយអភិវឌ្ឍន៏ផ្លូវគមនាគមនី បណ្តាញចរន្តអគ្គិសនី និងបណ្តាញទឹកស្អាតជាដើម ហើយលទ្ធផលនឹងជូនដំណឹងនៅពេលក្រោយ ។
- ផលប្រយោជន៏នៃពន្ធ: ក្រុមហ៊ុននឹងធ្វើការបង់ពន្ធជូនរដ្ឋនៅពេលដែលទទួលបានផលអំពីការធ្វើអាជីកម្មរ៉ែរបស់ខ្លួន។ ជាកំរៃពីការយកពន្ធនេះ រាជរដ្ឋាភិបាលនឹងអាចប្រើប្រាស់ថវិកាចំណូលនេះដើម្បីអភិវឌ្ឍន៏ភូមិ-ឃុំ និងសហគមន៏មូលដ្ឋាន ដោយស្របទៅតាមទិសដៅអភិវឌ្ឍន៏របស់រាជរដ្ឋាភិបាល ។

Draft

- សកម្មភាពបន្ទាប់៖ មកទល់បច្ចុប្បន្នក្រុមហ៊ុនមិនមានគំរោងអភិវឌ្ឍន៍អ្វីបន្ត ឬបន្ថែមទៀតទេ ក្រៅពីគំរោងធ្វើអាជីវកម្មរ៉ែនេះ។ ក្នុងករណីប្រសិនបើមាន ក្រុមហ៊ុននឹងធ្វើការជូនដំណឹងអាជ្ញាធរដែនដី និងប្រជាពលរដ្ឋមូលដ្ឋាន និងស្នើការសុំពីរាជរដ្ឋាភិបាល។
- សំណូមពរ៖ សុំឱ្យស្ថាប័នជំនាញពាក់ព័ន្ធ អាជ្ញាធរដែនដី និងប្រជាពលរដ្ឋមូលដ្ឋាន ជួយសហការ និងគាំទ្រដល់គំរោងអភិវឌ្ឍន៍របស់ក្រុមហ៊ុន ដើម្បីឱ្យបានដំណើរការទៅបានល្អ។

## ៥.៤. សន្និដ្ឋាន

ការស្ទង់មតិ ជួបប្រជុំពិភាក្សា និងពិគ្រោះយោបល់ជាមួយស្ថាប័នជំនាញ អាជ្ញាធរ និងសហគមន៍មូលដ្ឋាន ដែលពាក់ព័ន្ធដើម្បីប្រមូលនូវមតិសាធារណៈ និងស្វែងរកដំណោះស្រាយមួយដ៏ល្អ និងអាចទទួលយកបានសំរាប់ភាគីពាក់ព័ន្ធទាំងអស់អំពីបញ្ហាបរិស្ថាន និងសង្គម ដែលអាចបង្កឡើងដោយសារសកម្មភាពគំរោងធ្វើអាជីវកម្មរ៉ែដែករបស់ក្រុមហ៊ុន។ លទ្ធផលបានបង្ហាញឱ្យឃើញថា ភាគីពាក់ព័ន្ធដែលបានចូលរួមក្នុងកិច្ចពិគ្រោះយោបល់ មិនបានបង្ហាញនូវការជំទាស់ចំពោះវត្តមានគំរោងនេះទេ ព្រោះវាជាការសំរេចចិត្តរបស់រាជរដ្ឋាភិបាល (ប្រសិនបើទុកដីនេះចោលទំនេរវានឹងបាត់បង់ផលប្រយោជន៍ជាតិជាងការធ្វើវិនិយោគរបស់ក្រុមហ៊ុន) ប៉ុន្តែមានការបារម្ភ ជាពិសេសទៅលើការបាត់បង់ដីធ្លីសំរាប់ការដាំដំណាំ និងការបាត់បង់មុខរបររបស់ប្រជាពលរដ្ឋ និងធនធានព្រៃឈើ។ ជាមួយគ្នានេះដែរពួកគាត់ក៏បានសុំសំណូមពរឱ្យរាជរដ្ឋាបាល ក៏ដូចក្រសួង-ស្ថាប័នពាក់ព័ន្ធ និងក្រុមហ៊ុនជួយធ្វើការផ្សព្វផ្សាយ និងពន្យល់អំពីគោលបំណង និងសារៈប្រយោជន៍គំរោងដល់ប្រជាពលរដ្ឋ ដោះស្រាយដីធ្លីដែលប៉ះពាល់ឱ្យបានសមរម្យ រកវិធីសាស្ត្រឈូសឆាយព្រៃទៅតាមបទដ្ឋានបច្ចេកទេសដែលបានកំនត់ដោយស្ថាប័នដែលពាក់ព័ន្ធ និងសហការឱ្យបានស្អិតរមួតជាមួយអាជ្ញាធរដែនដី និងប្រជាពលរដ្ឋមូលដ្ឋាន និងស្ថាប័នដែលពាក់ព័ន្ធដើម្បីចៀសវាងនូវបញ្ហាសង្គមផ្សេងៗ ផ្តល់អាទិភាពការងារដល់ប្រជាពលរដ្ឋមូលដ្ឋាន ធានាសុវត្ថិភាពការងារជូនបុគ្គលិក-កម្មករ ព្រមទាំងជួយចូលរួមអភិវឌ្ឍន៍សហគមន៍មូលដ្ឋានដូចជា ជួយអភិវឌ្ឍន៍ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ-សង្គមជូនសហគមន៍មូលដ្ឋាន។ បន្ថែមពីនេះទៀត ក្រុមហ៊ុនត្រូវគោរពនូវកិច្ចសន្យា និងប្រតិបត្តិការងារនានារបស់ខ្លួនដូចជា ការឈូសឆាយដី ការសិក្សាស្រាវជ្រាវរុករករ៉ែ ការជីក យករ៉ែ ដំណើរការសាងសង់ និងការធ្វើសកម្មភាពអ្វីមួយឱ្យស្របទៅតាមប្លង់មេ និងបទដ្ឋានបច្ចេកទេស និងគោលការណ៍ច្បាប់។

Draft


អាជ្ញាធរស្រុកបរកែវ


អាជ្ញាធរស្រុកអូរយ៉ាដាវ


អាជ្ញាធរឃុំកិចុង


អាជ្ញាធរឃុំលំជ័រ


អាជ្ញាធរឃុំកក់


អាជ្ញាធរឃុំសោមធំ

Draft



អាជ្ញាធរ និងប្រជាពលរដ្ឋនៅក្នុងភូមិក្រៀល



អាជ្ញាធរ និងប្រជាពលរដ្ឋនៅក្នុងភូមិប្រឡៃ



អាជ្ញាធរ និងប្រជាពលរដ្ឋនៅក្នុងភូមិកាចក



អាជ្ញាធរ និងប្រជាពលរដ្ឋនៅក្នុងភូមិសោមគល់

**រូបភាព29.** ការផ្សព្វផ្សាយ និងការពិគ្រោះយោបល់ជាមួយអាជ្ញាធរដែនដី និងប្រជាពលរដ្ឋមូលដ្ឋាន

Draft



មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត



មន្ទីរបរិស្ថានខេត្ត



មន្ទីរកសិកម្មខេត្ត



មន្ទីរធនធានទឹក និងឧតុនិយមខេត្ត



ខ័ណ្ឌរដ្ឋបាលព្រៃឈើខេត្ត



សង្កាត់រដ្ឋបាលជលផលខេត្ត

**រូបភាព៣០.** កិច្ចប្រជុំពិភាក្សា និងពិគ្រោះយោបល់ជាមួយស្ថាប័នជំនាញ និងមន្ទីរពាក់ព័ន្ធ